ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-May-2017, 10:34
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៤៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ត្រាវិស ហ្វារ *(Mr. Travis FARR)*

កញ្ញា សុង ឆរ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វែនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ត្រាវិស ហ្វារ | អង់គ្លេស |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក សៅ ប៊ាន (2-TCW-807) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សៅ ហ៊ាន** (2-TCW-807)

សួរបន្តដោយលោក ត្រាវិស ហ្វារ ផ្ដើមពី ....................ទំព័រ ៣

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ....................ទំព័រ ២៣

សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្ដើមពី ....................ទំព័រ ២៤

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ....................ទំព័រ ៣២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៣៥

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សៅ ប៉ាន។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះគឺលោក សៅ ប៉ាន។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ រីឯសាក្សីបម្រុងនៅថ្ងៃនេះ មានរហស្សនាម 2-TCW-944។ សាក្សីរូបនេះបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅម៉ោងដប់ព្រឹកនេះមុននឹងមកផ្តល់សក្ខីកម្ម។ សាក្សីរូបនេះមានមេធាវីប្រឹក្សាលោក ឌុច ផារី។

សូមអរគុណលោកប្រធាន។

[០៩:០៦:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់លោកៗ នួន ជា

ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីខ្លួនមានលទ្ធភាពចូលរួមសវនាការនាពេលថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថាការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់ សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការបង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ឃើញថាស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះខ្លាំង ពេលៗអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថាសូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្ត អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីៗ ។ សូមអញ្ជើញ!

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្ដីលោកប្រធាន អស់លោក លោកស្រីចៅក្រម! អស់លោក លោកស្រីទាំងអស់សាធារណជន។

[០៩:០៩:១៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ត្រាវិស ហ្វារ៖**

**សៈ** ជម្រាបសួរលោក សៅ ប៉ាន។ ពីម្សិលមិញ នៅពេលមុនពេលបញ្ចប់វគ្គសៀល យើងនិយាយអំពីការចាប់ខ្លួនបងប្រុសរបស់លោក។ តើបងប្រុសរបស់លោកបានទៅដល់ភូមិរបស់លោកនៅ<ហ្នឹង រយៈពេលប៉ុន្មាន>ដែរ ក្រោយពីការដួលរលំទីក្រុងភ្នំពេញ?

**លោក សៅ ប៉ាន៖**

**ឆៈ** ក្រោយពីការរំលំដួលក្រុងភ្នំពេញ រយៈកាលពីភ្នំពេញមកដល់ផ្ទះ ចំនួនពីរបីថ្ងៃ។ មកដល់ផ្ទះបានពីរបីថ្ងៃ មេភូមិមេក្រុមគេ មកអញ្ជើញគាត់ទៅរៀនសូត្រ។

**សៈ** តើគេចាប់ខ្លួនគាត់ហ្នឹងរយៈពេលប៉ុនណាដែរបន្ទាប់<>ពីទៅដល់ភូមិហ្នឹងគេចាប់ខ្លួននៅពេលណា?

**ឆៈ** ពេលមកដល់ភូមិ ពេលចាប់ កាលនោះ ជំនាន់នោះ ខ្ញុំអត់បានដឹងថ្ងៃ ដឹងខែអីទេ។ ក្រោយបីថ្ងៃមក បានគេនាំខ្លួនទៅ មេភូមិអីគេយកខ្លួនទៅរៀនសូត្រ គេប្រាប់ប្រពន្ធកូនថាទៅរៀនសូត្រ បាត់រហូតតាំងពីពេលហ្នឹង។

[០៩:១០:៤៧]

**សៈ** តើលោកដឹងការចាប់ខ្លួនរបស់គាត់ហ្នឹងតាមរយៈអ្នកណា? តាមរយៈប្រពន្ធរបស់គាត់ ឬតាមរយៈក្រុមគ្រួសាររបស់គាត់? <ឬក៏លោកបានឃើញហេតុការណ៍ហ្នឹងដោយផ្ទាល់?>

**ឆៈ** ពេលមេភូមិ មេក្រុមមកចាប់ហ្នឹង គឺមានប្រពន្ធ មានម៉ែ បងប្អូននៅក្នុងហ្នឹង នៅក្នុងផ្ទះហ្នឹង។

**សៈ** ពីម្សិលមិញលោកនិយាយថា គាត់ត្រូវបានកងឈ្លបចាប់ខ្លួន។ តើលោកដឹងពីអ្នកណាថាកងឈ្លបហ្នឹងជាអ្នកចាប់ខ្លួន?

**ឆៈ** កងឈ្លបចាប់ខ្លួនដឹងពីបងថ្លៃដែលជាប្រពន្ធលោក លន់ ហាម នេះ។

**សៈ** នៅក្នុងចម្លើយ៤៦ លោកបាននិយាយថា៖ "ខ្ញុំបានដឹងថា មានទីតាំងសម្លាប់មនុស្សនៅក្រាំងតាចាន់។ បងប្រុសរបស់ខ្ញុំ លន់ ហាម ត្រូវបានគេចាប់ខ្លួនទៅក្រាំងតាចាន់"។ បញ្ចប់ការដកស្រង់។ សូមលោកជម្រាបផង ថាតើ<ហេតុដូចម្ដេចបានជាលោកដឹងថា>គេចាប់ខ្លួនបងប្រុសរបស់លោកយកទៅក្រាំងតាចាន់<>?

**ឆ៖** ពេលដែលដឹកនាំទៅ នាំតាមសម្រួល អត់មានចង មានអីទេ ជិះរទេះសេះទៅ។ ដែលខ្ញុំដឹងថា យកទៅសម្លាប់នៅក្រាំងតាចាន់។ ពេលក្រោយមកបានដឹង អ្នកជិតខាងគេប្រាប់ថា មានសម្លាប់នៅទីតាំងធំ – ក្រាំងតាចាន់។

**ស៖** តើលោកដឹងការចាប់ខ្លួនហ្នឹងនៅពេលណា?

**ឆ៖** ពេលថ្ងៃៗ។ ពេលនោះ ខែថ្ងៃឆ្នាំអី ខ្ញុំមិនដែលឃើញទេ មិនដែលមានថា ថ្ងៃនេះ ថ្ងៃចន្ទ ថ្ងៃសុក្រ ថ្ងៃអង្គារ អត់ខែឆ្នាំទេ អត់មានដឹងថ្ងៃអី ខែអីទេជំនាន់នោះ។ ដឹងតែកសិករ ធ្វើតែស្រែហ្នឹង។

[០៩:១៣:២១]

**ស៖** នៅក្នុងចម្លើយលេខ៣៥ លោកបានរៀបរាប់ថា បងប្រុសរបស់លោកធ្វើជាទាហានលន់ នល់។ តើគាត់មានឋានន្តរស័ក្តិមានបុណ្យស័ក្តិប៉ុនណាដែរ? <ហើយថាតើគាត់ធ្វើការនៅទីណាដែរ?>

**ឆ៖** ដែលគាត់ធ្វើទាហានលន់ នល់ ក្រោយមកបាក់បែកគ្នា មិនដែលស្គាល់ មិនដែលជួបគ្នារហូតដល់មកពេលដែលជួបគ្នាទេ យកទៅហ្នឹង ខ្ញុំអត់បានដឹងស័ក្តិប៉ុន្មានៗដែរ។

**ស៖** ខ្ញុំសូមសួរលោកមនុស្សចំនួនបី<នាក់ ដែលនៅក្នុងតំបន់របស់លោក> ទី១ឈ្មោះ <ពេជ> ចាន់, នួន ជិន ហើយនិង អ៊ុក ណារុន។ តើលោកស្គាល់មនុស្សទាំងបីនាក់នេះទេ? ហើយបើលោកស្គាល់ តើមានអ្វីកើតឡើងចំពោះអ្នកទាំងបីនាក់នេះ នៅក្នុងអំឡុងរបបខ្មែរក្រហម?

**ឆ៖** ឈ្មោះទាំងបីនាក់នេះ ខ្ញុំអត់បានស្គាល់ទាំងអស់។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរអំពីការចាប់ខ្លួនមួយផ្សេងទៀតនៅក្នុងចម្លើយ៤១នៃកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត លោកនិយាយដូចតទៅ សូមដកស្រង់៖ “នៅយប់មួយ ខ្ញុំបានឃើញគេហៅមនុស្សម្នាក់<ទៅជាមួយពួកគេ> តែខ្ញុំមិនចាំឈ្មោះទេ ដោយគេយកទៅវែកស្ពឹក ប៉ុន្តែអ្នកនោះបាត់ខ្លួនរហូត<។> ប្រធានឈ្លបប្រើឲ្យកូនឈ្លបរបស់គេមកហៅយកទៅ។ ប្រធានឈ្លបឈ្មោះ សៀម មិនដឹងថាគាត់ស្លាប់ឬក៏រស់ទេ ក្រៅពីនោះមានការបាត់ខ្លួនច្រើនទៀតតែខ្ញុំមិនចាំឈ្មោះទេ”។ បញ្ចប់ការដកស្រង់។ សូមលោកជួយជម្រាបប្រាប់អំពីប្រធានឈ្លបឈ្មោះ សៀម បន្តិចមើលថាតើគាត់ជាអ្នកណា? ហើយតើគាត់មានបានចូលពាក់ព័ន្ធក្នុងការចាប់ខ្លួននេះទេ?

[០៩:១៥:៤៤]

**ឆ៖** សូមជម្រាបជូនថាលោក សៀម នេះជាប្រធានឈ្លបនៅឃុំត្រាំកក់។ អ៊ីចឹងអ្វីៗដែលគាត់ត្រូវការគឺគាត់ប្រើឈ្លបគាត់ទៅហៅអ្នកណាមួយ ទៅនាំអ្នកណាមួយ គឺគាត់ប្រើតាមកូនឈ្លបគាត់ទៅ។

**លោក ត្រាវិស ហ្សារ៖**

លោកប្រធានខ្ញុំសូមការអនុញ្ញាតការបង្ហាញឯកសារជូនសាក្សី E3/2437, ERN 00366707 <>ជាអង់គ្លេស<,> 00271003<> ERNជាភាសាខ្មែរ<, ជាភាសាបារាំងគឺ> 00623848។ នេះជាឯកសារ១ដែលចុះហត្ថលេខាដោយឈ្មោះ សៀម នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧ <នៅត្រាំកក់ ហើយផ្ញើជូនទៅកាន់ប្រធានផ្នែកអំប់រំ, មន្ទីរស្រុក១០៥>។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន សូមអរគុណដែលផ្តល់វេទិកានេះឲ្យខ្ញុំ។ មុនពេលបង្ហាញឯកសារនេះជូនសាក្សី ខ្ញុំសូមឲ្យអនុញ្ញាតសហព្រះរាជអាជ្ញាបង្ហាញថាតើឯកសារនេះជាប់ពាក់ព័ន្ធទៅនឹងសាក្សីរូបនេះដោយរបៀបណា? ខ្ញុំដឹងថាមានឈ្មោះនៅក្នុងឯកសារហ្នឹង ក៏ប៉ុន្តែសូមឲ្យគាត់បញ្ជាក់មូលហេតុថា១ហេតុអីជាចាំបាច់ត្រូវបង្ហាញឯកសារហ្នឹងទៅសាក្សី <នៅពេលដែលគាត់បាននិយាយរួចហើយថាគាត់មិនពុំបានដឹងអំពីបញ្ហានេះទេ។>

[០៩:១៧:៣៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា បង្ហាញ បញ្ជាក់មើលយ៉ាងម៉េចទៅ? បំភ្លឺពីភាពពាក់ព័ន្ធនៃឯកសារក្នុងការភាពដឹងរបស់សាក្សីទៅនឹងឯកសារដែលលោកមានបំណងយកមកបង្ហាញនេះ វាមានទំនាក់ទំនងគ្នាយ៉ាងម៉េច?

**លោក ត្រាវិស ហ្សារ៖**

លោកប្រធានគឺអ៊ីចេះ! ទី១ នេះជាឯកសារដែលចុះហត្ថលេខាដោយប្រធានឈ្មួបឈ្មោះ សៀម ដែលសាក្សីនិយាយអម្បាញ់មិញ វាពាក់ព័ន្ធទៅនឹងការចាប់ខ្លួន<ផ្សេងទៀត។> នៅក្នុងចម្លើយរបស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេត <បាននិយាយថា៖ "មាន>មនុស្សជាច្រើន<ទៀតបានបាត់ខ្លួនក្រៅពីបុគ្គលម្នាក់នេះ> ប៉ុន្តែខ្ញុំមិនចាំឈ្មោះនោះ ទេ<">។ ដូច្នេះ<នៅក្នុងបរិបទនេះ គឺថា>ឯកសារនេះគឺ<សាក្សីប្រហែលជាអាចជួយឲ្យយើងយល់ច្បាស់លាស់ពីបរិបទនេះ បើសិនជាគាត់ត្រូវបាន

អនុញ្ញាតឲ្យមើលឯកសារនេះ>។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:១៨:៤៩]

**សួរដោយលោក ត្រាវិស ហ្វារ៖**

ហើយក៏សូមបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរលោកប្រធាន។

**ស៖** លោក សៅ ប៉ាន ខ្ញុំសូមផ្តល់ពេលវេលាឲ្យលោកពិនិត្យមើលឯកសារនេះដែលចុះហត្ថលេខា <ដោយ សៀម នៅ>ថ្ងៃទី២៩ ខែមេសា ១៩៧៧ នៅត្រាំកក់។ ខ្ញុំសូមអានផ្នែកខ្លីមួយនៃឯកសារនេះ ដែលនិយាយថា សូមដកស្រង់៖ "សមមិត្ត<>មន្ទីរអប់រំស្រុក១០៥ ជ្រាបជាព័ត៌មានដូចតទៅ សូមបញ្ជូនឈ្មោះ សំរិត ម៉ាត និងរាយការណ៍ពីសកម្មភាពរបស់វាជូនសមមិត្តដូចតទៅនេះ"។ បញ្ចប់ការដកស្រង់។ បន្ទាប់មកឯកសារនេះក៏បាននិយាយទៀតថាបុគ្គលនេះជាទាហាន <មានឋានន្តរស័ក្តិពលបាលឯក ហើយជាអ្នករិះគន់អង្គការ>។ ហើយសំណួរខ្ញុំ លោកសាក្សី តើលោកស្គាល់ឈ្មោះ សំរិត ម៉ាត នេះទេ? <តើលោកដឹងអ្វីខ្លះអំពីការចាប់ខ្លួនរបស់គាត់នេះ?>

**លោក សៅ ប៉ាន៖**

**ឆ៖** ខ្ញុំមិនស្គាល់ទេ។

**ស៖** សូមអរគុណ។ ឥឡូវ ខ្ញុំសូមទៅនិយាយអំពីសហករណ៍វិញម្តង។ នៅក្នុងចម្លើយលេខ២៤ នៃកិច្ចសម្ភាសន៍របស់លោក លោកត្រូវបានសួរថា "តើលោកចាំទេនៅពេលណាដែលគេបំបាត់ទ្រព្យសម្បត្តិឯកជន?" ហើយលោកនិយាយដូចតទៅ សូមដកស្រង់៖ "បន្ទាប់ពីបែកភ្នំពេញក្នុងឆ្នាំ១៩៧៥ ទ្រព្យសម្បត្តិទាំងអស់ដូចជា គោ ក្របី ស្រែ ផ្ទះសម្បែង ត្រូវបានយកដាក់រួមទាំងអស់។ ក្នុងការដាក់រួមនេះ ប្រជាជនមានប្រតិកម្មដែរ ប៉ុន្តែមិនហ៊ាននិយាយ ដោយខ្លាចគេយកទៅសម្លាប់ចោល"។ បញ្ចប់ការដកស្រង់។ សូមលោកជម្រាបថា សូមលោកជម្រាបលម្អិតមកអំពីដំណើរការប្រមូលទ្រព្យសម្បត្តិ ឯកជនដាក់រួមនេះ តើគេប្រមូលដោយរបៀបណា? ហើយអ្នកណាប្រមូល ជាអ្នកប្រមូល?

**ឆ៖** ខ្ញុំសូមជម្រាបជូន កាលដែលដាក់រួមគឺឆ្នាំ១៩៧៦។ ពេលនោះមេភូមិ គេហៅទៅប្រជុំប្រាប់ពន្យល់ប្រជាពលរដ្ឋតាមភូមិទាំងអស់ថា ទ្រព្យសម្បត្តិទាំងឡាយដែលមាន គឺដាក់សម្ហូហភាពទាំងអស់។ គោ ក្របី ផ្ទះសម្បែង ចាន ឆ្នាំង គឺអត់ឲ្យមានកម្មសិទ្ធិឯកជនចាប់តាំងពីថ្ងៃនោះមក។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:២១:៥៨]

**ស៖** សូមលោកប្រាប់ឈ្មោះប្រធានភូមិហ្នឹងផង បើសិនជាលោកចាំ?

**ឆ៖** ប្រធានភូមិទី១ ឈ្មោះ ទឹម, បន្ទាប់មកទី២ ឈ្មោះ គេហៅ អាចារ្យនាង១, ទី៣ តាឯក ប៉ុនស្លាប់អស់។

**ស៖** លោកបាននិយាយថា ប្រជាជនគឺថាមានប្រតិកម្មចំពោះការប្រមូលទ្រព្យដាក់<រួម>នេះដែរ ប៉ុន្តែគេមិនហ៊ានតវ៉ាអីទេ ដោយសារភ័យខ្លាចគេយកទៅសម្លាប់ចោល។ សូមលោកជួយជម្រាបផងមើល៍ថា តើប្រជាជនខ្លាចអ្នកណាយកទៅសម្លាប់ចោលហ្នឹង?

**ឆ៖** ប្រជាជនខ្លាចបំផុតរឿងមេភូមិ ហើយនិងឈ្លប។

**ស៖** នៅក្នុងចម្លើយលេខ២៥របស់លោក លោកបញ្ជាក់ថា ក្រោយថ្ងៃ១៧ មេសា ១៩៧៥ គេបានឲ្យលោកទៅធ្វើស្រែ។ អ្នកណាជាអ្នកចាត់តាំងឲ្យលោកទៅធ្វើស្រែនុង៎?

**ឆ៖** ខ្ញុំជម្រាបជូនម្តងទៀត។ ពេលដែលបញ្ជាឲ្យទៅធ្វើស្រែ ធ្វើអីហ្នឹងគឺមេភូមិ បានន័យថា មេកងចាត់ចែងហើយអស់តាមក្រុមនីមួយៗ ដាក់ទិសទៅខាងលិច ទៅខាងកើតៗ។

[០៩:២៤:០៤]

**ស៖** លោកចាំឈ្មោះប្រធានកងហ្នឹងទេ?

**ឆ៖** មួយកងណា? – ឈ្មោះ តាម៉ម ។

**ស៖** នៅក្នុងចម្លើយលេខ២៧ នៃកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត សូមដកស្រង់ "គេឲ្យយើងលើក<ភ្លឺ>ស្រែ ជាក្រឡាចក្រត្រង្គ ទោះបីជាមានភ្លឺទោល ឬភ្លឺភ្លោះ និង<ជីក>ប្រឡាយតូចធំ"។ បញ្ចប់ការដកស្រង់។ តើលោកអាចជម្រាបបានទេថា តើគេឲ្យលោករែកដី ឬក៏ជីកប្រឡាយ ឬក៏លើកទំនប់? តើកិច្ចការជាក់ស្តែងតែម្តង គេឲ្យលោកធ្វើអ្វី?

**ឆ៖** ការជាក់ស្តែង គេចាត់ចែងឲ្យខ្ញុំហ្នឹង ពេលលើកភ្លឺៗ ពេលភ្ជួរៗ ពេលទៅដាំដំណាំៗអីចឹងទៅ ពេលទៅចុះស្រែប្រាំងទៅៗ។ គ្រប់បែបយ៉ាងទាំងអស់ ផ្នែកកសិកម្ម។

**ស៖** តើគេឲ្យលោកធ្វើការ<នៅម៉ោងប៉ុន្មានដែរ>?

**ឆ៖** ផ្នែកកសិកម្មបើភ្ជួរក្នុងមួយហិកតា នង្គ័លបួន ម៉ោងពីរដណ្តប់ ម៉ោងមួយអីបានហើយ។ ពេលណាដែលគេវាយជួងចប់ៗ ដល់ម៉ោងគឺគេវាយជួង ដល់ម៉ោងហូបបាយតែម្តង កាលនោះខ្ញុំអីក៏គ្មានម៉ោងគ្មានអីមើលដែរ។

**ស៖** ហើយលោកធ្វើអ្វីទៀតដែរនៅពេលរសៀល?

**ឆ៖** មើលគោ ខែដកស្ទូង បើភ្ជួរហើយមួយហិកតាក្នុងមួយថ្ងៃៗរសៀល គឺមើលគោ ធ្វើម៉េចឱ្យគោឆ្អែត។ ពេលដល់ហូបបាយពេលយប់ ពេលចេញពីហូបបាយមក ឱ្យអ្នកភ្ជួរហ្នឹងដកសំណាបម្នាក់ប្រាំដំបទៀត។

**ស៖** អ៊ីចឹងការងារពេញមួយថ្ងៃហ្នឹងចប់នៅម៉ោងប៉ុន្មានលោក?

**ឆ៖** ការងារពេញមួយថ្ងៃចប់នៅម៉ោងប្រាំពីរ-ប្រាំបីយប់ ពេលដែលហូបបាយក្នុងសហករណ៍ហើយ។

**ស៖** តើមានពេលណាមួយដែលគេតម្រូវឱ្យលោកធ្វើការហួសពីម៉ោង ប្រាំពីរ <ឬប្រាំបី>ល្ងាចដែរទេ?

**ឆ៖** គ្មានទេ។

**ស៖** ក្នុងពេលដែលលោកធ្វើស្រែ តើលោកអាចចាកចេញពីកងបានទេ ប្រសិនណាជាលោកចង់ចេញពីកងទៅណានោះ?

**ឆ៖** មិនបានទេ។

[០៩:២៧:៣៩]

**ស៖** ហេតុអ្វីក៏មិនបាន? ហើយលោកគិតថាវាអាចនឹងមានអ្វីកើតឡើងដែរទេ?

**ឆ៖** ខ្ញុំចាប់តាំងពីរស់ក្នុងរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ខ្ញុំអត់ដែលសុំមេកង មេក្រុមណាទៅណាផង។ គេដាក់នៅត្រង់ណាធ្វើត្រង់ណាធ្វើត្រង់ហ្នឹង។

**ស៖** ហើយ ចុះហេតុអ្វីបានជាលោកមិនដែលបានសុំមេកងទៅណាម្តងអ៊ីចឹង?

**ឆ៖** ខ្ញុំខ្លាចៗមែនទែនហ្នងរឿងមេកង ហើយមិនខ្ញុំដែលសួរនិយាយជាមួយមេកងបានមុនទេ តែដាក់ផែនការអី ខ្ញុំធ្វើផែនការហ្នឹងដល់ហើយៗ មានតែមេកងមកទាក់ទងប្រាប់ ប្រជុំប្រាប់ថាទៅខាងលិច ទៅខាងកើត ទៅធ្វើទីនេះ ទីនោះ មានតែប៉ុណ្ណឹងទេ។

**ស៖** ហេតុអ្វីបានជាលោកខ្លាចមេកង?

**ឆ៖** ខ្លាចៗមែនទែនខ្ញុំ ព្រោះឃើញគេយកមនុស្សទៅបាត់ៗអ៊ីចឹងខ្លាច។ មួយថ្ងៃណាដែលខ្ញុំអត់ហ៊ាននិយាយមួយម៉ាត់ផង។ និយាយតែជាមួយអ្នកកងភ្ជួរ ដាំដំណាំជាមួយគ្នាតិចតួចហ្នឹង។

**ស៖** នៅពេល<>លោកឃើញគេចាប់ខ្លួនមនុស្សយកទៅ តើលោកដឹងទេថាហេតុអ្វីបានជាគេ

ចាប់ខ្លួនអ្នកទាំងនោះ?

**ឆ៖** ខ្ញុំអត់បានដឹងមូលហេតុៗអី រឿងអីៗទេ ខ្ញុំអត់បានដែលដឹងដែរស្រាប់តែបាត់ៗពីកងទៅ ហើយឃើញយកទៅ។

**ស៖** ខ្ញុំគិតថាលោកបាននិយាយអំពីទិន្នផលស្រូវ គឺថា តើសមាជិកកងរបស់លោកត្រូវគេដាក់ទណ្ឌកម្មអត់ទេ បើសិនណាជាយើងមិនសម្រេចទិន្នផលដែលគេចង់បានទេ?

**ឆ៖** ពេលដែលបង្កបង្កើត--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប សាក្សី។

សូមអញ្ជើញមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយតំណាងសហព្រះរាជអាជ្ញាលើកពីការសន្និដ្ឋានមួយក្នុងលក្ខខណ្ឌមិនច្បាស់លាស់ ថាប្រសិនបើមាន -- មិនបានទិន្នផលស្រូវ ថាតើនឹងមានការដាក់ទណ្ឌកម្មទេ? ហើយសំណួរនេះវាធ្វើជាឧបមានវិធីដែលឲ្យសាក្សីធ្វើការសន្និដ្ឋាន។ ដូច្នេះ ខ្ញុំសូមជំទាស់បាទ។

**លោក គ្រាវិស ហ្វារ៖**

លោកប្រធាន ខ្ញុំមិនគិតថាវាជាសំណួរឧបមានវិធីទេ។ ខ្ញុំសួរគាត់អំពីករណីជាក់ស្តែងតែម្តងដែលថាបើ<កម្មករ> គឺថាមិនអាចសម្រេចបរិមាណហ្នឹងបានទេ តើវាមានអ្វីកើតឡើងដល់អ្នកទាំងនោះដែរឬក៏អត់?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣១:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ បដិសេធនូវសេចក្តីជំទាស់នេះ ហើយសាក្សីឆ្លើយតបទៅនឹងសំណួរ ដែលសួរដោយសហព្រះរាជអាជ្ញារងអន្តរជាតិចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើនៅចាំសំណួរ។ បើមិនចាំទេ សហព្រះរាជអាជ្ញារងសួរម្តងទៀត។

**លោក គ្រាវិស ហ្វារ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រហែលជាខ្ញុំសួរឡើងវិញ លោកប្រធាន។

**សួរដោយលោក ត្រាវិស ហ្សារ៖**

**ស៖** លោកសាក្សី សូមលោកជម្រាបថាតើមានអ្វីកើតឡើងទៅកម្មករ <>នៅក្នុង<កង> របស់លោក ប្រសិនណាជាគេមិនអាចសម្រេចបរិមាណណាមួយបាននោះទេ?

**លោក សៅ ប៊ាន៖**

**ឆ៖** បាទ ផែនការអង្គការឲ្យធ្វើស្រូវ បានន័យថាកសិករហ្នឹង ក្នុងមួយហិកតាធ្វើយ៉ាងម៉េច ពេលអង្គប្រជុំ ធ្វើយ៉ាងម៉េចឲ្យបានបីតោនទៅបួនតោន ក្នុងមួយហិកតា។ ពេលដែលដល់ច្រូតកាត់ៗ ខ្ញុំក៏អត់បានដឹងថា គេយកទៅវាល់ យកទៅវាស់ យកទៅថ្លឹងថ្លែងឯណាដែរ។ ហើយក្នុងភាពដែលបាន ឬ មិនបាន គ្រប់ផែនការនោះ ខ្ញុំអត់ដែលមានប្រតិកម្មអីទេ នៅក្នុងកងខ្ញុំ។

**ស៖** លោកទើបនិយាយអំពីទិន្នផលបីតោនក្នុងមួយហិកតា នៅក្នុងចម្លើយ៣០របស់លោក លោកនិយាយ<ថា> លោកបានចូលរួម<ការប្រជុំ> ដែលគេ<ប្រាប់លោក>ថា ឲ្យលោកខិតខំធ្វើការដើម្បីសម្រេចបានទិន្នផលបី<ទៅបួន>តោនក្នុង<មួយ>ហិកតា”។ ក្នុងនាមជាកសិករធ្វើស្រែមួយជីវិត តើលោកគិតថាគេអាចសម្រេចទិន្នផលបានអ៊ីចឹងទេ នៅក្នុងទឹកដីរបស់លោកហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួរនេះ គឺលើសពីសមត្ថភាពរបស់សាក្សីរូបនេះហើយ។ <ខ្ញុំអាចធានាចំពោះអ្នកថា -- អំពីចំនួនហិកតា -- តើអ្វីរឿងសមហេតុផល តើអ្វីដែលអ្នកអាចរំពឹងទទួលបានចំនួនប៉ុន្មានតោនក្នុងមួយហិកតា។> គឺវាៗអាស្រ័យទៅលើ<កត្តាជីវសាស្ត្រ។ ឥឡូវ យើងកំពុងធ្វើ>សម្រេចបានទិន្នផល <១៦>តោនក្នុងមួយហិកតា <បើខ្ញុំយល់មិនច្រឡំទេ>។ ដូច្នេះ <វាលើសហើយ ដែលសួរសំណួរទៅកាន់កសិករម្នាក់អំពីទិសដៅ>សម្រេចបាន ឬក៏<> បីតោនក្នុងមួយហិកតា។ <វាគឺជាសំណួរសម្រាប់អ្នកជំនាញ មិនមែនសំណួរសម្រាប់សាក្សីរូបនេះទេ>។

[០៩:៣៥:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៧:០៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍ ឆ្លើយតបនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីចំពោះសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចំពោះមូលហេតុដែលមេធាវីការពារក្តីលើកឡើងគឺថា អង្គជំនុំជម្រះ<នឹងមិនពឹងផ្អែកទៅលើការរកឃើញពិត>ណាមួយ <ចំពោះចម្លើយរបស់សាក្សីនោះទេ។> ប៉ុន្តែមិនមែនមានន័យថា សាក្សីមិនអាចឆ្លើយបាននោះទេ គឺថាអាចមានលទ្ធភាពឆ្លើយបាន។ <ហើយអង្គជំនុំជម្រះចង់ស្តាប់ចម្លើយនេះ។>

**សួរដោយលោក ត្រាវិស ហ្វារ៖**

**ស៖** ដូច្នេះ ខ្ញុំសូមសួរឡើងវិញលោកសាក្សី។ លោក សៅ ប៊ាន ចំពោះកសិករណាម្នាក់ដែលធ្លាប់ធ្វើស្រែមុនឆ្នាំ១៩៧៥ តើគេអាចសម្រេចគោលបំណង ៣តោន <ទៅ៤តោន ក្នុង>១ហិកតា បានដែរទេមុនឆ្នាំ១៩៧៥?

**លោក សៅ ប៊ាន៖**

**ឆ៖** តាមខ្ញុំពិនិត្យតាមដាន ខ្ញុំជាកសិករមួយដែរ មិនដែលបានពីរតោនទៅបីតោន ហើយម៉្យាងទៀត ក៏មិនដែលថ្លឹងដែរ មិនដែលបាន ពិតជាមិនដែលបានពីរតោនបាទ បីតោនទេនៅក្នុងមួយហិកតាមិនបានទេ។

**ស៖** ឥឡូវខ្ញុំសូមសួរសំណួរមួយចំនួនចំពោះចំណីអាហារដែលលោកបានទទួល នៅពេលដែលលោកនៅសហករណ៍។ ពេលលោកទៅហូបបាយ លោកទៅហូបនៅឯណា?

[០៩:៣៨:៥១]

**ឆ៖** ពេលហូបបាយ ទៅហូបនៅសហករណ៍។ ក្នុងមួយតុ ១០នាក់ បាយមួយកន្ធអីចឹងមក ស្លមកគោមអីចឹងមក គ្នា១០នាក់ តែប៉ុណ្ណឹង។

**ស៖** ហើយនៅកន្លែងដែលលោកហូបបាយហ្នឹង តើមានអ្នកដទៃប៉ុន្មាននាក់ដែរទៅហូបបាយជាមួយលោក?

**ឆ៖** ពេលទៅហូបបាយ រៀងរាល់ថ្ងៃ ទាំងមូលដ្ឋាន ទាំង១៧ គឺហូបជួបគ្នារៀងរាល់ថ្ងៃ រៀងរាល់ពេលបាយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅចម្លើយ៣៣ លោកបាននិយាយថា <ខ្ញុំសូមដកស្រង់៖ "របបអាហារទទួលបាន គឺបបររាវ ហើយពេលខ្លះ គឺមានបាយបន្តិចបន្តួច ប៉ុន្តែយើងហូប>មិនឆ្អែត<ទេ គឺមានបបរមួយចានធំសម្រាប់គ្នាចំនួន>១០នាក់ក្នុងមួយតុ<">។ តើ របបអាហារ<ហ្នឹង វាមានប៉ះពាល់អ្វីខ្លះទៅដល់សុខភាពរបស់កម្មករ>នៅសហករណ៍<>?

**លោក វិចទ័រ កូប៉េ៖**

លោកប្រធាន <>គាត់មិន<>មែនជាអ្នកជំនាញទេ<។ គាត់អាចនិយាយ>អ្វីកើតឡើងចំពោះ<គាត់ប៉ុណ្ណោះ។ ចំពោះសំណួរថា ហេតុអ្វីបានជាគាត់ទទួលបានបបរមិនគ្រប់គ្រាន់ ប៉ុន្តែគាត់មិនអាចមានលទ្ធភាពឆ្លើយអ្វីដែលប៉ះពាល់ទៅដល់សុខភាពរបស់សមាជិកផ្សេងទៀតនៅក្នុងសហករណ៍របស់គាត់>នោះទេ។

**សួរដោយលោក ត្រាវិស ហ្វារ៖**

ខ្ញុំសូមរៀបចំសួរលោកឡើងវិញ។

**ស៖** លោក សៅ ប៉ាន សូមលោកជម្រាបមើល៍ថា តើរបបអាហារហ្នឹងវាមានការប៉ះពាល់ទៅដល់សុខភាពរបស់លោក ឬក៏សុខភាពរបស់អ្នកដទៃទៀតដែល<លោកមានការប្រាស្រ័យទាក់ទងផ្ទាល់>ដែរទេ?

**លោក សៅ ប៉ាន៖**

**ឆ៖** ពេលដែលហូបបាយ ក្រោយមកខ្លះហូបអត់ឆ្អែត មិនឆ្អែតទាំងអស់គ្នា និយាយរួមមិនឆ្អែតទាំងអស់គ្នា។ ក្រោយមកខ្លះសុខភាពខ្សោយ ខ្លះហើមអ៊ីចឹងទៅ។ ពេលដែលហើមអ៊ីចឹង ទៅពេទ្យទៅអីទៅណាអ៊ីចឹងបាត់ទៅ ខ្ញុំក៏អត់ដឹងដែរ។ ជួនកាលគេចុះចែកថ្នាំតាមកង តាមក្រុមអ៊ីចឹងទៅ ថ្នាំគេនោះថ្នាំគេបង្កើតខ្លួនឯងនៅក្នុងភូមិឃុំ។

[០៩:៤១:៣៤]

**ស៖** តើប្រជាជនប៉ានត្អូញត្អែរប្រាប់មេសហករណ៍ ឬក៏ថ្នាក់ដឹកនាំណាមួយដែលថាពួកគាត់មិនទទួលបានអាហារគ្រប់គ្រាន់ទេ?

**ឆ៖** ដាច់ខាតមិនប៉ាន រអ៊ូរទាំនឹងគ្នាឯងធ្វើការជាមួយគ្នា អត់ប៉ានដាច់ខាត មាត់មិនប៉ាមាត់និយាយអត់ប៉ាននិយាយ និយាយមិនបាន។ តែនិយាយឮដល់គេក្រុមនៅជិតខាងហ្នឹង បាត់ខ្លួនហើយយប់ឡើងបាត់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅក្នុងចម្លើយ៤២ នៃកិច្ចសម្ភាសន៍ជាមួយសហថៅក្រមស៊ើបអង្កេត លោកបាននិយាយថា សូមដកស្រង់៖ "សូម្បីតែអ្នកដែលមានទំនាស់នឹងការហូបមិនឆ្អែត ធ្វើឱ្យបាក់ស្លាបព្រា បាក់នង្គ័លក៏ចាត់ទុកថាជាខ្មាំងដែរ"។ បញ្ចប់ការដកស្រង់។ លោកដឹងទេ ហេតុអ្វីបានជាអ្នកដែលមានទំនាស់ទាស់អ្នកដែលមានទំនាស់ថាហូបមិនឆ្អែតអ៊ីចឹង ថាចាត់ទុកថាខ្មាំង?

**ឆ៖** ទម្លាប់គណៈកង មេកងគេ គេនិយាយតែអ៊ីចឹង។ គំរាមតែអ៊ីចឹងរហូត។

[០៩:៤៣:០២]

**លោក ត្រាវិស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារជូនសាក្សី គឺឯកសារ E3/4127, ERN ជាភាសាខ្មែរ 00270806, ERN ជាភាសាអង់គ្លេស 00362229 ហើយបារាំង 00632505។ នេះជាឯកសារមកពីស្រុកត្រាំកក់ គឺចុះថ្ងៃទី១៧ ខែមករា ៧៨ រាយការណ៍អំពីអ្នកដែល<ត្រូវគេចាប់ខ្លួនដោយសារ>ត្អូញត្អែរអំពី<របបអាហារ>នេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ត្រង់ចំណុចនេះ ខ្ញុំចង់ឱ្យសហព្រះរាជអាជ្ញាបង្ហាញថាតើទំនាក់ទំនងរវាងឯកសារហ្នឹង ហើយនិងសាក្សីនេះនៅត្រង់ណា។ ខ្ញុំយល់ថាគាត់និយាយពីព័ត៌មានមួយស្រដៀងគ្នា ក៏ប៉ុន្តែថាគាត់ធ្វើដូចឯកសារមុនអ៊ីចឹង គាត់អត់បានបង្ហាញ ចង់និយាយថាមិនបាច់បង្ហាញឯកសារទៅសាក្សីទេដើម្បី<ចោទ>សំណួរ។ បើសិនជាគាត់ចង់ចោទសំណួរលើអ្នកណាម្នាក់ជាក់លាក់នោះ ត្រូវតែសួរទៅសាក្សីជាដំបូងថាស្គាល់បុគ្គលនោះដែរឬទេ ហើយបន្ទាប់មកផ្ដល់ឯកសារតាមក្រោយ។ អ៊ីចឹងមិនចាំបាច់ឱ្យសាក្សីហ្នឹងមានឯកសារនៅក្នុងដៃហើយ ដើម្បីឆ្លើយទៅនឹងសំណួរទេ។ អ៊ីចឹងខ្ញុំសូមជំទាស់អំពីវិធីសាស្ត្រធ្វើដូច្នោះ។ ព្រោះធ្វើអ៊ីចឹង ឃើញថាគាត់ធ្វើអ៊ីចឹងដដែល ដោយពុំបង្ហាញពីទំនាក់ទំនងរវាងសាក្សី ហើយនិងឯកសារ។ អ៊ីចឹងគិតតែអានឯកសារហ្នឹងឱ្យសាក្សីរហូត មិនមានប្រយោជន៍អីទេ មិនមែនជាវិធីសាស្ត្រល្អទេ។ មិនអាចធ្វើឱ្យយើងរកឃើញការពិតទេ លោកប្រធាន ធ្វើយ៉ាងដូច្នេះ។

[០៩:៤៥:០០]

**លោក ត្រាវិស ហ្វារ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកប្រធាន នៅក្នុងសំណើរបស់ខ្ញុំ គឺវាមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ឯកសារនេះ សាក្សីទើបបាននិយាយថាប្រជាជនមានការនិយាយអំពី ត្អូញត្អែរអំពីចំណីអាហារ អ្នកត្អូញត្អែរគឺបានបាត់ខ្លួន។ ហើយឯកសារនេះជាឯកសារមកពីតំបន់របស់គាត់ <គឺមកពីត្រាំកក់។> ឯកសារនេះមាននិយាយលម្អិត <អំពី>ឈ្មោះបុគ្គល<ម្នាក់។ សេចក្ដីលម្អិតទាំងអស់ដែលយើងដាក់បង្ហាញនេះ គឺអាចជួយរំឭកការ>ចងចាំរបស់សាក្សី។ <ច្បាស់ណាស់ ដោយសារតែពេលវេលាកន្លងយូរមកហើយ ដូច្នេះយើងព្យាយាមរកវិធីសាស្ត្រ ដោយលើកឡើងនូវឈ្មោះនោះ គឺ>ប្រហែលជាវាអាចនឹងជួយសាក្សី <អាចមានលទ្ធភាពក្នុងស្រាយបំភ្លឺខ្លឹមសារនៃឯកសារនេះជូន>អង្គជំនុំជម្រះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សូមមានប្រតិកម្មជំទាស់។ ប្រសិនបើយើងពិនិត្យមើលអំពីឯកសារក្រាំងតាចាន់ <ដោយខ្ញុំហៅថាឯកសារទូទៅនោះ> ប្រសិនបើវាមានយថាភាព <អ្នកអាចអានថា គ្មាននរណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយសារតែគាត់ត្អូញត្អែរអំពីអាហារនោះទេ។ ពេលខ្លះ វាបានលើកឡើង អ្នកត្អូញត្អែរអំពីអាហារ> ក៏ប៉ុន្តែវាមានបរិបទទូលំទូលាយជាងនេះ។ វាមានការចោទប្រកាន់ទាក់ទងទៅនឹងដែលជាប់ពាក់ព័ន្ធទៅនឹងវៀតណាម បញ្ហាដូចជាការលួចអ្វីមួយពីសហគមន៍ ការអានខ្លឹមសារតែមួយ<ផ្នែក>ពីឯកសារនេះគឺ<ថាសូម្បីតែ>សាក្សីមិនទាំងដឹងផង ហើយទើបវាមិនមានន័យអ្វីផង។

**ប្រធានអង្គជំនុំ៖**

ឈប់ឲ្យឆ្លើយឆ្លងអស់សិនទៅ! ឥឡូវអញ្ជើញឆ្លើយឆ្លងគ្នាឲ្យចប់សិនទៅ! អញ្ជើញត្រូវការអីទៀតទេ? ខាងភាគីដើមចោទព្រះរាជអាជ្ញា អ៊ំ! អាដែងមេធាវីមានអីទៀតទេ? អញ្ជើញនិយាយឲ្យអស់ម្ដងទៅ!

[០៩:៤៧:០៨]

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ លោកប្រធាន បើតាមចម្លើយរបស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ ខ្ញុំកាន់តែមានមូលហេតុជំទាស់ទៀតព្រោះគាត់កំពុងតែពន្យល់យើងថា គាត់ពុំមានចេតនាក្នុងការផ្ដល់ឈ្មោះបុគ្គលដែលៗគាត់ចង់ឲ្យអានឯកសារហ្នឹងទៅសាក្សី ហើយគ្រាន់តែចង់រំឭកឲ្យចងចាំទេ។ យើងមិនអាចធ្វើអ៊ីចឹងបានទេ ព្រោះថាតាំងពីដើម ព្រោះថាពីដើមមក យើងមិនដឹងថាគាត់ចង់និយាយពីបុគ្គលហ្នឹងនោះទេ អ៊ីចឹងវាលើសពីហ្នឹងទៀត គឺថាហាក់ដូចជាផ្ដល់ព័ត៌មានឲ្យសាក្សីអ៊ីចឹង។ ខ្ញុំគិតថាខ្ញុំប្រហែលជានិយាយញាប់

ពេកហើយ ព្រោះថាគាត់ឃើញថាលោកចៅក្រម ហ្វេនស៍ ហ្នឹងគាត់ញាក់ភ្នែក អ៊ីចឹងខ្ញុំនិយាយឲ្យយឺតជាងហ្នឹងបន្តិច។ អ៊ីចឹងគ្រាន់តែចង់និយាយថា ការអនុវត្តនៅកន្លែងយើងនេះ យើងចង់រំឭកសាក្សីនោះ យើងត្រូវតែដឹងថាតើគាត់មានចង់និយាយ ឬក៏ស្គាល់បុគ្គលដែលយើងចង់និយាយព្រឹត្តិការណ៍ទាក់ទងគាត់ដែរឬក៏អត់? តែក្នុងករណីយើងនេះ សាក្សីនេះគ្រាន់តែចង់និយាយជាៗទូទៅអំពីអ្នកដែលត្រូវបានចាប់ខ្លួន យើងពុំមានភស្តុតាងថាសាក្សីនេះស្គាល់បុគ្គលនោះទេ គឺថាក្នុងឯកសារគេនិយាយពីគាត់នោះ។ អ៊ីចឹងចំពោះខាងការពារក្តី យើងថាយើងមិនអាចប្រើឯកសារហ្នឹងរំឭកការចងចាំសាក្សីនោះទេ។ <> បើយើងមិនដឹងថាបុគ្គលដែលឯកសារហ្នឹងនិយាយ<ហ្នឹង គឺជាបុគ្គលដែលសាក្សីស្គាល់នោះទេ> យើងមិនអាចប្រើវិធីសាស្ត្រនេះបានទេ។ អ៊ីចឹងជាបឋមយើងត្រូវតែធ្វើ យើងត្រូវតែធ្វើ យើងត្រូវតែឆ្លងកាត់តាមដំណាក់កាលដំបូងបង្កើតជាមូលដ្ឋានសិន ឥឡូវនេះយើងអត់មានបង្កើតមូលដ្ឋានអីទេ យើងលោតមួយជំហាន រំលងមួយជំហានហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាអន្តរជាតិ មានអីឆ្លើយតបទេ?

**លោក ត្រាវិស ហ្វារ៖**

ពិតហើយ គឺខ្ញុំមានបំណងប្រាប់ឈ្មោះបុគ្គលនេះដែលមាននៅក្នុងឯកសារនេះទៅដល់សាក្សីរូបនេះ ប៉ុន្តែវាមានចំណុចលម្អិតបន្ថែមអំពីឧបទ្ទវហេតុនេះផង។ ដើម្បីឲ្យសាក្សីមានយល់បានច្បាស់ពេញលេញ ហើយខ្ញុំគិតថាវាធ្វើឲ្យសាក្សីអាចនឹងនិយាយអ្វីមួយបានត្រឹមត្រូវសុក្រឹត <ថាតើគាត់ចាំរឿងនេះ ឬក៏អត់>។ នេះជាសំណួរពាក់ព័ន្ធ<ច្រើន>ទៅនឹង<ឧបទ្ទវហេតុមួយ ជាជាងសួរ>ពាក់ព័ន្ធទៅនឹងបុគ្គលជាក់លាក់ម្នាក់។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥២:៥២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន។ បាទ អង្គជំនុំជម្រះ ចង់ជម្រាបជូនថា នៅពេលដែលឯកសារមានភាពពាក់ព័ន្ធដើម្បីសួរសាក្សីមួយលើប្រធានបទដែលគាត់ស្គាល់ ឯកសារហ្នឹងអាចប្រើបាន។ ការអនុ

វត្ថុបែបនេះ មានផលប្រយោជន៍មួយ គឺថានៅពេលដែលមេធាវីអន្តរជាតិ ឬក៏សហព្រះរាជអាជ្ញាអន្តរជាតិចោទសំណួរ អាចមានបញ្ហាទាក់ទងឈ្មោះជាភាសាខ្មែរ។ ដូច្នេះ អ៊ីចឹង នៅពេលដែលយើងឲ្យអានជាភាសាដើម គឺទៅសាក្សីនោះ គឺថាអាចធ្វើឲ្យយើងជៀសផុតពីបញ្ហាបកប្រែ។ ហើយម្យ៉ាងទៀត អង្គជំនុំជម្រះមានការព្រួយបារម្ភដែរ អំពី<អង្គហេតុនៃសំណួរជាក់លាក់>មួយចំនួន ស្ថានភាពការពិត <ប្រហែលជាការពិបាកក្នុងការបង្ហាញ ដូច្នេះក្នុងការបង្ហាញ>ឯកសារដើមទៅសាក្សីនោះ <>គឺថាយើងអាចតំណាងឲ្យស្ថានភាពនុ៎ះបានដោយត្រឹមត្រូវ <ដោយចៀសវាងនូវការភាន់ច្រឡំបាន>។ ដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើឯកសារនេះ ក្នុងពេលឥឡូវនេះបាទ។

[០៩:៥៤:១៥]

**លោក ត្រាវិស ហ្វារ៖**

ខ្ញុំសូមបង្ហាញឯកសារនេះ នៅលើអេក្រង់កុំព្យូទ័រផង លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក ត្រាវិស ហ្វារ៖**

លោក សៅ ប៉ាន ដូចលោកបានឃើញឯកសារនេះហើយ គឺឯកសារនេះជូនទៅសមមិត្តគណៈមន្ទីរអប់រំស្រុក១០៥។ ឯកសារនេះចុះកាលបរិច្ឆេទថ្ងៃទី១៧ មករា ៧៨ ចុះហត្ថលេខាដោយឈ្មោះ <នុន>។ តើលោកមានចាំឈ្មោះកម្មាភិបាលខ្មែរក្រហម ឬមេដឹកនាំណាម្នាក់ឈ្មោះ <នុន> នៅស្រុកត្រាំកក់ដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ មិនស្គាល់។

**ស៖** ឥឡូវនេះខ្ញុំសូមអានឯកសារនេះ ជូនលោកស្ដាប់ គឺឯកសារនិយាយថា៖ "យើងបានចាប់បញ្ជូនប្រជាជនថ្មីម្នាក់ឈ្មោះ សុក សែ នៅភូមិត្រាំកក់ ឃុំត្រាំកក់ ឈ្មោះ សុក សែ នេះ បានលើកទំនាស់កាលពីថ្ងៃទី១៤ ខែមករា ថាគេប្រើដូចសត្វតិរច្ឆាន ធ្វើស្រូវបាន<ពេញ>ជង្រុក ឲ្យបាយស៊ីមិនឆ្អែត"។ <បញ្ចប់ការដកស្រង់។ បន្ទាប់>ទៀត <គាត់បានត្អូញត្អែរអំពីការ>ដាំដំឡូង <នៅក្នុង>ខែហ្នឹង <ហើយគាត់បាននិយាយថា ហេតុអ្វីបានជាយើងត្រូវធ្វើ>តាមអីអាខ្លាំងអស់ហ្នឹង <ដែលវាមិនដឹងស្អីសោះហ្នឹង។ ហើយបន្ទាប់មកទៀត> បន្តដកស្រង់មកទៀត៖ "ហេតុដូច្នេះគណៈស្រុកបាន<សម្រេចនិង>បញ្ជាមកឲ្យយើងចាប់ខ្លួនបុគ្គលនេះ និងបញ្ជូនមកកន្លែងសមមិត្តបង"។ បញ្ចប់ការដកស្រង់។ អ្វី

ដែលខ្ញុំចង់សួរលោកសាក្សី តើលោកសាក្សីមានបានដឹងអំពីព្រឹត្តការណ៍កើតទៅលើបុគ្គល ឈ្មោះ សុក សែ នេះទេ? ដោយសារតែការត្អូញត្អែរអំពី<រឿងទាំងអស់>នេះ។

**ឆ៖** សូមមិនឆ្លើយ។ អត់បានដឹង អត់បានស្គាល់ សុក សែ។

**ស៖** សូមអរគុណ។ <លោកអាចជម្រាបយើងថា តើនៅពេលណា>សហករណ៍ត្រូវបានបង្កើតឡើងនៅស្រុកត្រាំកក់<?> តើប្រជាជន <មានសេរីភាពក្នុងការធ្វើស្រែចម្ការ និងដាំអ្វីដែលពួកគាត់ចង់ដាំដែរ ឬទេ? ឧទាហរណ៍ថា តើលោកអាច>ដាំបន្លែបង្កា <ឬក៏ផ្លែឈើ>ដើម្បីហូបផ្ទាល់ខ្លួនដែរទេ នៅពេលណាឃ្លាន?

**ឆ៖** ឲ្យដាំ ប៉ុន្តែគេមានសេដ្ឋកិច្ចគេប្រមូល ហាមអត់ឲ្យហូបចុកទេ។

[០៩:៥៧:៤៩]

**ស៖** នៅក្នុងចម្លើយ៣៦ ជូនសហចៅក្រមស៊ើបអង្កេត លោកនិយាយថាប្រជាជនជាច្រើនឈឺ ដូចជា ជំងឺ<គ្រុនក្តៅ និង> រាករូស។ តើមានថ្នាំគ្រប់គ្រាន់សម្រាប់ព្យាបាលអ្នកទាំងអស់នេះទេ?

**ឆ៖** គ្មាន។

**ស៖** តើលោកអាចជម្រាបបាន ថាអ្នកដែលកើតជំងឺគ្រុនក្តៅ រាករូសហ្នឹង វាយ៉ាង -- ជួបបញ្ហាយ៉ាងម៉េចដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន តើសាក្សីនេះ <>ជាបុគ្គលិកពេទ្យ <ឬ>វេជ្ជបណ្ឌិត<? ចំពោះសំណួរ "ទទួលបានការព្យាបាលគ្រប់គ្រាន់"> អ៊ីចឹងធ្វើម៉េចបានគាត់ដឹងទៅបាន?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៩:០៦]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់លោកមេធាវីក្នុងសំណួរនេះមិនត្រឹមត្រូវទេ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់នេះ។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយសហព្រះរាជអាជ្ញារងចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើសាក្សីចងចាំ។

**លោក សៅ ប៉ាន៖**

**ឆ៖** បញ្ហាឈឺថ្កាត់ រាករូស គ្មានៗថ្នាំ តាមកង តាមក្រុមគ្មាន ឃើញថ្នាំវាឲ្យអាដូចគ្រាប់អី ដូច

អាចម៍ទន្សាយហ្នឹង គេបុកធ្វើខ្លួនគេ សង្គមកិច្ចគេធ្វើហ្នឹង យកទៅចែកតិចៗអីចឹងទៅ។ ជាក៏ជា បើមិនជាអត់ទៅ។ មិនដែលឃើញថ្នាំពេទ្យច្បាស់ទេ។

**សួរដោយលោក គ្រាវិស ហ្សារះ**

**ស៖** ឥឡូវហ្នឹង ខ្ញុំសូមសួរលោកសំណួរមួយចំនួនទាក់ទងទៅនឹងខ្មាំងផ្ទៃក្នុង។ នៅក្នុងចម្លើយលេខ៤២ គេបានសួរលោកដូចតទៅ សូមដកស្រង់៖ "នៅពេលប្រជុំ តើគេមាននិយាយអំពីការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុងដែរឬទេ"។ បញ្ចប់ការដកស្រង់។ ចម្លើយរបស់លោក សូមដកស្រង់៖ "គឺមានសូម្បីតែមានអ្នកទំនាស់អំពីការហូបមិនឆ្អែត ការធ្វើឲ្យបាក់ស្ពាបព្រា បាក់នង្គ័ល ក៏គេចាត់ទុកជាខ្មាំងដែរ។ នៅក្នុងពេលប្រជុំ ខ្ញុំមិនដែលឃើញគេចាប់មនុស្សទេ"។ បញ្ចប់ការដកស្រង់។ ខ្ញុំបានសួរលោកពីខាងដើម និយាយអំពីអ្នកដែលមានទំនាស់ចំពោះការហូបមិនឆ្អែត។ ចុះអ្នកធ្វើឲ្យបាក់ស្ពាបព្រា បាក់នង្គ័ល ហេតុអីក៏គេចាត់ទុកថាជាខ្មាំងដែរ?

[១០:០១:0៥]

**ឆ៖** តាមអង្គប្រជុំម្តងៗ ពេលគេប្រជុំ គឺមេកងគេនិយាយភាសាហ្នឹងក្នុងអង្គប្រជុំឲ្យប្រជាពលរដ្ឋស្តាប់ តែប៉ុណ្ណឹង។

**ស៖** លោក គាត់ប្រាប់លោកថាម៉េចដែរ តាមដែលលោកចាំ?

**ឆ៖** ដែលខ្ញុំចាំ បើកាលណាបាក់នង្គ័ល បាក់ស្ពាបព្រា អាហ្នឹងគេនិយាយថា ខ្មាំងក្នុងជួរតែម្តង ខ្មាំងក្នុងសហករណ៍។ និយាយតែប៉ុណ្ណឹងភាសាគេ។

**ស៖** លោកនិយាយអំពីប្រជាជនដែលទំទាស់តវ៉ាអំពីចំណីអាហារ ឬក៏ធ្វើឲ្យបាក់<>នង្គ័ល <ត្រូវបានគេចាត់ទុកថាជាខ្មាំងផ្ទៃក្នុង។> តើលោកមានចាំថា មនុស្សប្រភេទណាទៀតត្រូវគេចាត់ទុកថា ខ្មាំងផ្ទៃក្នុងដែរទេ ក្នុងពេលប្រជុំហ្នឹង?

[១០:0២:២0]

**ឆ៖** ក្នុងពេលប្រជុំ គេនិយាយតែភាសា បាក់ លួចចំណីចំណុក បាក់ស្ពាបព្រា បាក់នង្គ័ល គេនិយាយតែភាសា "ខ្មាំង" តែប៉ុណ្ណឹង។

**ស៖** លោកនិយាយថា ប្រធានកងនិយាយនៅក្នុងពេលប្រជុំ តើលោកនៅចាំថាមានអ្នកណាផ្សេងទៀត និយាយក្នុងពេលប្រជុំនោះដែរទេ?

**ឆ៖** អត់ដែលមានប៉ាននិយាយតវ៉ាអី អត់ មានតែមេកង ហើយនិងអនុកងអីចឹង។ គេនិយាយ

មានតែប៉ុណ្ណឹង។

**ស៖** លោកក៏បាននិយាយថា លោកមិនឃើញគេចាប់ខ្លួននៅក្នុងពេលប្រជុំនោះទេ នៅពេលដែលគេប្រជុំនិយាយអំពីខ្មាំងស៊ីរូងផ្ទៃក្នុងនេះ។ តើលោកមានដឹង<អំពីស្ថានភាពរបស់អ្នកណាម្នាក់ដែលត្រូវបាន>គេចាប់ខ្លួន<> ដោយសារមានទំនាស់អំពី<អាហារ> ឬការបាក់ស្មាបព្រា ឬបាក់នង្គ័លនោះដែរទេ?

**ឆ៖** បាទ អត់ដែលឃើញ។ ពេលគេចាប់ មិនដឹងគេផ្សំរឿងអីខ្លះ ខ្ញុំអត់បានឃើញ។

**ស៖** ឥឡូវហ្នឹង ខ្ញុំសូមសួរសំណួរលោកពាក់ព័ន្ធទៅនឹងរូបព្រះពុទ្ធបដិមា <និងការប្រតិបត្តិសាសនាព្រះពុទ្ធ> ចន្លោះពីឆ្នាំ១៩៧៥ ទៅ ៧៩។ សូមលោកជម្រាបជូនតុលាការថា មានអ្វីកើតឡើងទៅនឹងវត្តអារាម ក៏ដូចថាមានអ្វីកើតឡើងទៅនឹងរូបព្រះពុទ្ធបដិមា <នៅក្នុងតំបន់របស់លោក អំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩>ដែរ?

[១០:០៤:២៩]

**ឆ៖** ពេលដែលខ្ញុំឃើញក្រោយបំផុត រូបបដិមា វត្តអារាមអី គេយកចេញអស់ហើយ សៀវភៅធម៌ សៀវភៅអី អត់មានឃើញ។ ខ្ញុំមានឃើញប្រធានក្រុមមួយយកទៅចែកឱ្យសមាជិកក្រុមហ្នឹង ធ្វើក្រដាសជក់។

**ស៖** នៅក្នុងចម្លើយលេខ៤៥ លោកនិយាយថា៖ "វត្តត្រូវបានគេយកទៅធ្វើជាមន្ទីរពេទ្យ រោងជាង"។ តើលោកអាចផ្តល់ឧទាហរណ៍ណាជាក់លាក់ វត្តណាដែលត្រូវបានគេយកទៅធ្វើជាមន្ទីរពេទ្យ ធ្វើរោងជាងហ្នឹង?

**ឆ៖** នៅឃុំត្រាំកក់ វត្តឯកឧត្តមមួយយកទៅដាក់រោងជាង នៅសាលាឆាន់ ក្នុងវត្តឯកឧត្តមដាក់រោងជាង។ ក្រៅពីនោះ មានដាក់ចង្ក្រានតូចៗខ្លះដែរ នៅវត្តថ្មកែវ។ នេះខ្ញុំចាំបានប៉ុណ្ណឹង។

**ស៖** លោកដឹងទេ មានអ្វីកើតឡើងចំពោះព្រះសង្ឃនៅក្នុងតំបន់របស់លោក ក្នុងអំឡុងពេលហ្នឹង?

**ឆ៖** ព្រះសង្ឃនៅតំបន់របស់ខ្ញុំ ខ្ញុំអត់មានដឹងកើតឡើងរឿងអីទេ ដឹងតែឃើញថានាំលោកទៅផ្សឹកអស់ចេញពីវត្ត ឆ្នាំ១៩៧៥-៧៦ហ្នឹង។

**ស៖** លោកដឹង<រឿងហ្នឹងដោយរបៀបណា>ដែរ?

**ឆ៖** ខ្ញុំឃើញបណ្តើរលោកទៅផ្សឹក។ បណ្តើរលោកចេញពីវត្តទាំងអស់ទៅផ្លូវអីចឹង ទៅជើង

ទៅ។

[១០:០៦:៥៨]

**ស៖** <តើ>លោកស្គាល់វត្តអង្គរការ ឬក៏វត្តចម៉្បា<ទេ?> ហើយប្រសិនបើលោកស្គាល់ លោកអាចជម្រាបបានទេ ថាគេយកវត្តទាំងពីរនោះទៅធ្វើអ្វីដែរនៅក្នុងពេលនោះ<?>

**ឆ៖** ខ្ញុំស្គាល់វត្តអង្គរការ។ វត្តទាំងពីរហ្នឹងខ្ញុំស្គាល់ ប៉ុន្តែខ្ញុំមិនបាន ទៅដល់គេធ្វើអីៗ ខ្ញុំអត់បានឃើញ ព្រោះខ្ញុំនៅឃុំផ្សេង។

**ស៖** លោកចាំតើធ្លាប់មានគេនិយាយប្រាប់ថា <លោកត្រូវបាន>អនុញ្ញាតឲ្យប្រតិបត្តិគោរពសាសនា<នៅក្នុងអំឡុងពេល>ហ្នឹងដែរឬអត់ទេ? <ហើយបើមាន តើគេប្រាប់លោកអ្វីខ្លះដែរ?>

**ឆ៖** ពេលអំឡុងរយៈកាលបីឆ្នាំជាងហ្នឹង គ្មាននិយាយរឿងសាសនា គ្មាននិយាយអីរឿងគោរពអីអត់មានទាំងអស់ អត់ឲ្យមានជំនឿ អរូបអី អត់ឲ្យមានជំនឿទាំងអស់។

**ស៖** អ្នកណាប្រាប់លោកមិនឲ្យជឿពីជំនឿអរូបិយអីហ្នឹង?

**ឆ៖** ពេលប្រជុំម្ដងៗ មេកង មេក្រុម គេនិយាយថា អត់ឲ្យមានជឿ ស្ពោះផ្តុំហ្នឹង អរូបិយ អត់ឲ្យមានជឿ អ្នកតា ជាព្រលឹង ព្រះភូមិទាំងអស់ អត់ឲ្យមានជឿ។

**ស៖** ឥឡូវខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការរៀបការចន្លោះពីឆ្នាំ១៩៧៥ ដល់៧៩។ នៅក្នុងចម្លើយលេខ៤៣ លោកបាននិយាយអំពីការរៀបការតែម្ដង មាន១០ទៅ២០គូ គេឲ្យទៅប្ដេជ្ញា។ ខ្ញុំសូមដកស្រង់៖ "គេបានឲ្យអ្នកទាំងនោះទៅប្ដេជ្ញា" បញ្ចប់ការដកស្រង់។ តើការ -- តាមលោកយល់ តើគេប្ដេជ្ញាថាម៉េច ហើយប្ដេជ្ញាដើម្បីអី?

**ឆ៖** តាមខ្ញុំសួរអ្នកដែលប្ដេជ្ញា គេគ្រាន់តែឲ្យឆ្លើយថាប្ដេជ្ញាយកអ្នកនេះ អ្នកនោះអស់មួយជីវិតអីចឹងនិយាយម្ដងម្នាក់អីចឹង។ ខាងប្រុសគេនិយាយថាយកនាងឯងអស់មួយជីវិត។ ខាងនារីគេថាយកបុរសហ្នឹងអស់មួយជីវិត។ តែប៉ុណ្ណឹងភាសាគេ សួរតាមអ្នកដែលប្ដេជ្ញាទាំងប៉ុន្មានហ្នឹង។ ម៉ែឪបងប្អូនអីគេអត់ឲ្យបៀតទេ ពេលប្ដេជ្ញាម្ដងៗ ១០គូ ២០គូហ្នឹង។

[១០:១០:០៨]

**ស៖** លោកទើបតែបានលើកឡើងថា "ប្រជាជនទាំងនេះត្រូវបានគេសួរថាតើព្រមយកអ្នកណាម្នាក់ជាគូស្រករ"។ <នរណាសួរពួកគេថា តើពួកគេព្រមទទួលយកអ្នកណាម្នាក់ជាគូស្រករ>?

**ឆ៖** ខ្ញុំអត់បានដឹងទេ ត្រង់ពាក្យភាសាថា "គេប្រកែកមិនព្រម" ខ្ញុំអត់បានដឹង។ ខ្ញុំដឹងថាគេ

ប្ដេជ្ញា ហើយសួរអ្នកប្ដេជ្ញាគេឆ្លើយយ៉ាងម៉េច ប្ដេជ្ញា ហើយមានអីខ្លះ? គេឆ្លើយថាអត់មានអីទេ មានតែមេកង គណៈកង គណៈឃុំគេ។ មានតែប៉ុណ្ណឹង។

**ស៖** លោកក៏បាននិយាយផងដែរថាឪពុកម្ដាយ និងសាច់ញាតិមិនអនុញ្ញាតឲ្យៗចូលរួមនៅក្នុងពិធីរៀបការនេះ។ តើ<ធ្លាប់មានអ្នកណាម្នាក់>ពន្យល់<លោកថា> ហេតុអីបានជាគេមិនឲ្យឪពុកម្ដាយសាច់ញាតិចូលរួម?

**ឆ៖** ខ្ញុំអត់បានដឹង អត់បានយល់ទេបញ្ហាហ្នឹង។

**ស៖** សូមលោកជម្រាបមើលដែលមានកងមួយគេហៅថា "កងមេម៉ាយ" នៅក្នុងសហករណ៍របស់លោក។ តើមានទេ?

**ឆ៖** មាន។

**ស៖** សូមលោកប្រាប់បន្តិចមើលថាតើ កងហ្នឹងជាកងអ្វីដែរ? ធ្វើអ្វីដែរ?

**ឆ៖** "កងមេម៉ាយ" តាមខ្ញុំធ្លាប់ឃើញនៅឃុំខ្ញុំ មេម៉ាយណាដែលគេយកប្ដីបាត់ទៅ ទី១។ ទី២ មេម៉ាយណាដែលស្រាប់ពីយូរមកអាហ្នឹងរើងនារី គេដាក់មួយកង មុំទៅ អ្នកមានកម្លាំងៗមុំទៅ គេហៅថា "កងនារី កងពិសេស"។ អ៊ីចឹងអ្នកដែលមានកូនតូចតាច គេដាក់កងអ៊ីចឹងទៀតទៅ ធ្វើស្រែស្ទូង ដក ដាំដំណាំ ដូចគ្នាទាំងអស់ ផ្នែកកសិកម្មធ្វើទាំងអស់ ទាំងមេម៉ាយចាស មេម៉ាយក្មេងអីហ្នឹង។

[១០:១២:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ត្រាវិស ហ្សារ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ បង្ហាញជូនសាក្សីនូវឯកសារ E3/2057, ERN 00079142 ដល់ 43 <> ជាភាសាខ្មែរ, 00276586 ដល់ 87 <> ជាភាសាអង់គ្លេស<, ERN ជាភាសាបារាំង> 00848201 ដល់ 202។ នេះជាឯកសារមកពីស្រុកត្រាំកក់ ចុះថ្ងៃទី០៤ ខែកុម្ភៈ ១៩៧៨ ដែលនិយាយអំពី "កងមេម៉ាយ" ដែលសាក្សីទើបនិយាយអម្បាញ់មិញនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក ត្រាវិស ហ្សារ៖**

ហើយយើងខ្ញុំក៏ស្នើសុំដាក់បញ្ចាំងឯកសារនៅលើអេក្រង់កំព្យូទ័រផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ត្រាវិស ហ្សារ៖**

**ស៖** លោក សៅ ប៊ាន ដូចខ្ញុំបានទើបតែលើកឡើងថា ឯកសារនេះ ចុះថ្ងៃទី០៤ ខែកុម្ភៈ ១៩៧៨ ឯកសារមកពីស្រុកត្រាំកក់។ ខ្ញុំសូមឲ្យលោកផ្តោតតែផ្នែកដែលមានប្រអប់ដែលគេគូសជារង្វង់ព័ទ្ធជុំវិញ ហើយខ្ញុំសូមអានសម្រង់នេះ។ ឯកសារ និយាយសភាពការណ៍ខ្លាំងនៅៗមូលដ្ឋានឃុំត្រាំកក់មានដូចតទៅ៖ "យើងខ្ញុំបានក្តាប់បាននូវនៅក្នុងកងមេម៉ាយប្រមូលផ្តុំ វាមានផែនការប្រមូលផ្តុំកម្លាំងមួយ.ឈ្មោះ ខៀវ ទូច ជាមេ, ពីរ.ឈ្មោះ ឌឹម វ៉ាន់នី, បី. អ៊ីវ៉ាន់, បួន.ឈ្មោះ ប៊ុច សុក។ ទាំងបួននាក់នេះជានារីថ្មី ប្តីអង្គការកម្ទេចចោលហើយ"។ ហើយឯកសារនេះបន្តទៅទៀតថា ដោយមានការចោទប្រកាន់ផ្សេងៗប្រឆាំងទៅនឹងស្ត្រីមេម៉ាយទាំងអស់នោះ រួមមានផែនការធ្វើឃាតដល់មេកង <និងអាច

ដាក់ថ្នាំបំពុលប្រជាជនទៀត>ផង។

សំណួររបស់ខ្ញុំមិនពាក់ព័ន្ធទៅនឹងការចោទប្រកាន់នេះទេ គឺគ្រាន់តែសួរថា តើលោកស្គាល់នារីណាម្នាក់ក្នុងចំណោមនារីទាំងបួន ដែលខ្ញុំទើបតែរៀបរាប់ឈ្មោះអម្បាញ់មិញទេ?

[១០:៤០:២២]

**ឆ៖** ខ្ញុំបាទអត់បានស្គាល់ទាំងបួននាក់នេះទេ។

**ស៖** សូមអរគុណលោក សៅ ប៉ាន។

**លោក ត្រាវិស ហ្សារ៖**

លោកប្រធានខ្ញុំសូមធ្វើការអនុញ្ញាត សូមជូនវេទិកានេះជូនទៅតំណាងសហព្រះរាជអាជ្ញាជាតិ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងជាតិ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពភាគី ហើយនិងសាធារណជនដែលមានវត្តមាននៅក្នុងសវនាការនេះ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ សុង ឆវ័ន្ត តំណាងសហព្រះរាជអាជ្ញាជាតិ។ ខ្ញុំមានសំណួរតូចមួយចំនួន ដើម្បីចង់សួរបញ្ជាក់លើលោក។ លោកសាក្សីលោកបានផ្តល់សក្ខីកម្មជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5518 នៅត្រង់សំណួរចម្លើយលេខ២៩ លោកបានសួរឆ្លើយថា “សំណួរ៖ តើគណៈស្រុក គណៈតំបន់មានឈ្មោះអ្វីដែរ? ចម្លើយ២៩ លោកបានឆ្លើយថា ដកស្រង់៖ “គណៈស្រុកមានឈ្មោះ តាសាន រស់នៅ ប៉ុន្តែមិនដឹងច្បាស់ថានៅសំឡូត ឬប៉ៃលិន ឬអន្លង់វែងទេ។ ចំណែកគណៈតំបន់ខ្ញុំមិនចាំទេ។ ខ្ញុំចាំថាឈ្មោះ តាម៉ុក ដែលស្រុកកំណើតរបស់គាត់នៅឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ។ ក្រៅពីនេះខ្ញុំមិនចាំទេ”។ លោកថាគណៈស្រុកមានឈ្មោះ តាសាន តើលោកនៅចាំទេ ថាតាសានគាត់ធ្វើគណៈស្រុកក្នុងឆ្នាំណាដែរ?

**លោក សៅ ប៉ាន៖**

**ឆ៖** ខ្ញុំអត់បានចាំទេៗ តាសាន ព្រោះខ្ញុំដឹងថាក្រោយមកដឹងថាគណៈស្រុក។

**ស៖** ចុះដឹង ចុះលោកដឹងទេថាអ្នកណាជាអនុរបស់ តាសាន?

**ឆ៖** បាទអត់ដឹង។

**ស៖** ចុះគណៈស្រុកមុន តាសាន លោកស្គាល់ទេ ហើយគាត់មានឈ្មោះអ្វីដែរបើលោកស្គាល់?

**ឆ៖** បាទ អត់ស្គាល់។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណ។ លោកប្រធានខ្ញុំមិនសំណួរអ្វីបន្ថែមទេ សូមអរគុណ។

[១០:៤២:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់វេទិកា ជូនទៅក្រុមសហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណ លោកប្រធាន។ ជាដំបូងនាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ជម្រាបសួរលោកសាក្សី នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ នាងខ្ញុំមានសំណួរខ្លះៗដើម្បីចោទសួរទៅកាន់លោក និងសុំធ្វើការបញ្ជាក់បន្ថែម បន្ទាប់ពីលោកបានឆ្លើយកាលពីម្សិលមិញនិងថ្ងៃនេះ។ សំណួររបស់ខ្ញុំជាដំបូងសូមសួរលោកថា តើលោកមានស្គាល់ឈ្មោះប្រធានសហករណ៍ត្រាំកក់ទាំងមូលដែលឬទេ? បើលោកស្គាល់តើប្រធានសហករណ៍នោះ ឈ្មោះអ្វីដែរ?

**លោក សៅ ប៊ាន៖**

**ឆ៖** ប្រធានសហករណ៍ខ្ញុំស្គាល់។

**ប្រធានអង្គជំនុំ៖**

មេធាវីតាំងសួរ តាំងសំណួរបន្តទៀត!

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមសួរលោកបន្តទៀតថាតើលោក -- តើនៅក្នុងសហករណ៍ទាំងមូលហ្នឹង ប្រធាន

របស់សហករណ៍ហ្នឹង គេមានធ្វើការផ្លាស់ប្តូរពីប្រធានមួយទៅប្រធានមួយ ឬក៏មានតែប្រធានម្នាក់ហ្នឹងទេ ក្នុងអំឡុងពេលពីឆ្នាំ១៩៧៥ ដល់ ៧៩ នោះ? គេមានធ្វើការផ្លាស់ប្តូរអត់?

**ឆ៖** គ្មានទេ។

[១០:៤៥:០០]

**ស៖** សូមអរគុណ ខ្ញុំសូមធ្វើការបន្តសំណួរខ្ញុំទៀត។ កាលពីម្សិលមិញ លោកបានលើកឡើងទាក់ទងទៅនឹងប្រជាជន ប្រភេទប្រជាជន ហើយក្នុងនុំង ក្នុងចំណោមប្រភេទប្រជាជនហ្នឹង មានប្រជាជន -- លោកបានលើកអំពីប្រជាជនថ្មី។ អ៊ីចឹង ខ្ញុំសូមសួរលោកថាតើប្រជាជនថ្មីហ្នឹង គាត់មានសិទ្ធិសេរីភាពនៅក្នុងការដើរហើរដែរឬទេនៅក្នុងសហករណ៍ត្រាំកក់ហ្នឹង? ឬក៏នៅឃុំដែលលោករស់នៅ?

**ឆ៖** ពេលអំឡុងបីឆ្នាំផ្លាយហ្នឹង ទាំងមូលដ្ឋាន ទាំងថ្មី គ្មានសិទ្ធិដើរហើរពីផ្ទះមួយទៅផ្ទះមួយ។

**ស៖** ចុះនៅក្នុងពេលដែលប្រជាជនចង់ធ្វើដំណើរឆ្លងពីសហករណ៍មួយទៅសហករណ៍មួយ ឬក៏ភូមិមួយ -- អ៎! ស្រុកមួយទៅស្រុកមួយ។ តើគាត់អាចធ្វើដំណើរដូច្នោះបានអត់? ឬមួយក៏ទាល់តែមានការអនុញ្ញាត ឬក៏និតិវិធីអីដែលមានការសុំការអនុញ្ញាត ឬក៏អត់? ឬក៏យ៉ាងម៉េចដែរ ដើម្បីធ្វើការឆ្លងកាត់បាន?

[១០:៤៦:២៩]

**ឆ៖** ការងារឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយ ខ្ញុំអត់ដែលឃើញមានថាសុំអី ឮអី ខ្ញុំអត់ដែលឃើញមាន។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរទាក់ទងទៅនឹងការប្រាស្រ័យទាក់ទងរវាងសាច់ញាតិវិញម្តង។ សួរថាតើនៅក្នុងរបបហ្នឹង ប្រជាជននៅក្នុងសហករណ៍ត្រាំកក់ទាំងមូលហ្នឹង មានសិទ្ធិក្នុងការប្រាស្រ័យទាក់ទងរវាងសាច់ញាតិបងប្អូនរបស់ខ្លួនដែរឬទេនៅក្នុងពេលនុំង ដូចជាការទៅសួរសុខទុក្ខ ឬក៏ទំនាក់ទំនងរវាងឪពុក និងកូនអី អាចធ្វើ -- មានការអនុញ្ញាតឲ្យធ្វើដូច្នោះដែរឬទេ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

ឆ្លើយតបសាក្សី។ អំមិញលោកឆ្លើយ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ លោកឆ្លើយតបសំណួរចុងក្រោយអម្បាញ់មិញនេះ។

**លោក សៅ ប៊ាន៖**

**ឆ៖** ប្រាស្រ័យទាក់ទងទៅស្រុកមួយ ទៅភូមិមួយ ទៅសហករណ៍មួយ គ្មានៗ គ្មានសិទ្ធិ។

[១០:៤៧:៥០]

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** កាលពីម្សិលមិញលោកបានលើកឡើងថា នៅពេលដែលគេជម្លៀសប្រជាជនពីភ្នំពេញមកស្រុកត្រាំកក់នោះ លោកឃើញថាអ្នកខ្លះគេមានបងប្អូនទៅ គេក៏ទៅរស់នៅជាមួយបងប្អូនរបស់គេ។ ឯចំណែកអ្នកខ្លះទៀត គាត់ទៅសង់ខ្ទមរស់នៅដោយខ្លួនឯង ដោយកន្លែងហ្នឹងវាមិនមែនជាស្រុកភូមិរបស់គាត់ទេ។ អ៊ីចឹង ខ្ញុំចង់សួរលោកថាតើប្រជាជនដែលមិនមែនជាស្រុកភូមិ ដែលគាត់ទៅហ្នឹង មិនមែនជាស្រុកភូមិរបស់គាត់ហ្នឹង គាត់អាចធ្វើការផ្លាស់ប្តូរទៅភូមិកំណើតរបស់គាត់វិញបានដែរឬទេ នៅក្នុងអំឡុងពេលហ្នឹង? ព្រោះដោយសារការដែលគាត់ជម្លៀសទៅហ្នឹង វាមិនមែនចំគោលដៅដែលគាត់ចង់ទៅហ្នឹងណ៎ា អ៊ីចឹងគាត់ចង់ធ្វើការផ្លាស់ប្តូរទៅនៅស្រុកភូមិគាត់ ទៅនៅជាមួយបងប្អូនគាត់វិញបានដែរឬទេនៅក្នុងពេលនុ៎ង?

**ឆ៖** ពេលកំពុងដែលជម្លៀសពីភ្នំពេញមក មកដល់ស្រុកភូមិដែលគ្មានបងប្អូន កំពុងហ្នឹង កំពុងពេលហ្នឹងអាចគេស្នាក់ទុកអស់ទៅ អាចសុំបានទៅ ពេលកំពុងដែលឆ្វេចឆ្វាច ពេញទឹកពេញដីហ្នឹងអាចទៅបាន។ ពេលដែលគេរៀបភូមិរៀបកងហើយ អត់បានទេ។

[១០:៤៩:១០]

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តសំណួរទាក់ទងទៅនឹងការធ្វើស្រែបន្តិច។ ខ្ញុំសួរបញ្ជាក់លោកថាតើប្រជាជនចាស់ និងប្រជាជនថ្មីហ្នឹង គេឲ្យធ្វើស្រែរួមគ្នា ឬក៏ដាច់ដោយឡែកពីគ្នា?

**ឆ៖** ពេលដែលមានសហករណ៍ហើយ ធ្វើស្រែគឺរួមគ្នា។ មូលដ្ឋានអ្នកកាន់នង្គ័លកាន់អី ភ្ជួររាស់ឲ្យកងនារី កងប្រមូលផ្តុំ អ្នកស្ទូង អ្នកដក។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរបន្តទៀត ថាតើនៅក្នុងអំឡុងពេលដែលប្រជាជនធ្វើការភ្ជួរស្រែហ្នឹង តើមានការឃាម មានឈ្លបឬក៏មេភូមិ មេឃុំ អីគេឃាមកាមទៅលើការធ្វើស្រែហ្នឹងដែរឬទេ?

**ឆ៖** គ្មានទេ។ មានតែមេក្រុម មេកង គេនៅពិនិត្យហ្នឹង។

**ស៖** លោកមានដឹងពីមូលហេតុអី បានជាគេតម្រូវឲ្យមេក្រុម និងមេកង ឬក៏មេក្រុមនៅៗត្រួតពិនិត្យនៅក្នុងការធ្វើស្រែហ្នឹង?

**ឆ៖** គោលការណ៍ជំនាន់នោះ គឺត្រូវមានមេក្រុម មេកង ដើរត្រួតពិនិត្យតាមការដ្ឋាននីមួយៗជា

រៀងរាល់ថ្ងៃរាល់ពេលអ៊ីចឹង។

**ស៖** ចុះលោកសូមបញ្ជាក់ម្តងទៀត ថាតើមូលហេតុអីបានជាគេចាំបាច់ធ្វើការដើរត្រួតពិនិត្យការដ្ឋាន ឬក៏ស្រែទាំងហ្នឹង?

**ឆ៖** យុទ្ធសាស្ត្រកាលជំនាន់ហ្នឹង គឺផែនការគេធ្វើតែអ៊ីចឹង រៀងរាល់ថ្ងៃ រៀងរាល់ខែ រៀងរាល់ឆ្នាំអ៊ីចឹង ធ្វើតែអ៊ីចឹង។ កងនេះគេតាមដាន កងនោះៗទៅតាមមើលក្រែងលោកន្លែងណាដែលវ៉ៃមិនដាច់ ធ្វើមិនជឿនលឿន ធ្វើមិនប្រឹង ធ្វើមិនខំតាមជានិច្ចកាលអ៊ីចឹង។

**ស៖** ចុះលោកមានដែលធ្លាប់ឃើញ ឬក៏ធ្លាប់ឮអីទេ ថាតើនៅក្នុងអំឡុងពេលដែលប្រជាជនធ្វើស្រែហ្នឹង គាត់ដូចថាអ្នកខ្លះគាត់អស់កម្លាំង គាត់មិនអាចធ្វើស្រែបានទេ អ៊ីចឹងគាត់ទន់ដៃទន់ជើងអីអ៊ីចឹងទៅណ៎ា។ តើមានហេតុការណ៍អីកើតឡើងចំពោះបុគ្គលហ្នឹងដែរឬទេ?

[១០:៥២:១៨]

**ឆ៖** ខ្ញុំអ្នកកម្មករ ខ្ញុំមិនដែលឃើញ ខ្ញុំតែភ្លូរហើយខ្ញុំដើរចេញ។

**ស៖** លោកមិនដែលឃើញ ឬក៏លោកធ្លាប់ឃើញដែរ តែគ្រាន់តែថាលោកមិនៗៗចង់ដឹងចង់ឮរឿងហ្នឹង?

**ប្រធានអង្គជំនុំ៖**

សូមកុំអាលទាន់ឆ្លើយតបសាក្សី។

**លោក សៅ ប៉ាន៖**

**ឆ៖** ខ្ញុំដែលតែដឹងថាបាត់ពីកងពីក្រុម។

**ស៖** ចុះលោកមានដឹងមូលហេតុអីបានជាគាត់បាត់ពីកងពីក្រុមដែរឬទេ? បុគ្គលដែលបាត់ខ្លួនពីកងពីក្រុមនោះ?

**ឆ៖** ពេលដែលចូលមកក្នុងកងក្នុងក្រុមវិញ ខ្ញុំសួរមើលថាម៉េចបាត់ទៅណា? អស់កម្លាំងហេវហត់ រាក ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ តើការបាត់របស់គាត់ហ្នឹង គឺជាការបាត់ខ្លួនរហូត ឬក៏មានអ្នកខ្លះបាត់ខ្លួនរហូតហើយ ឬមួយក៏មានអ្នកខ្លះទៀតបាត់ខ្លួនហើយត្រឡប់ចូលមកធ្វើការដ្ឋានវិញ? សូមលោកជួយបំភ្លឺជូនអង្គសវនាការ។

**ឆ៖** បាត់ក្នុងការឈឺថ្កាត់ រាករូសអីតិចតួច កាលណាជាឃើញមកវិញ។ អត់ដែលបាត់រហូត

ទេ។

**ស៖** សូមអរគុណ។ ឥឡូវនាងខ្ញុំសូមបន្តទៅសំណួរទាក់ទងទៅនឹងរបបអាហារម្ដង។ លោកបានជម្រាបជូនអង្គសវនាការអំពីរបបអាហារទាក់ទងទៅនឹងប្រជាជន ប៉ុន្តែឥឡូវនេះនាងខ្ញុំចង់សួរថា តើទាក់ទងទៅនឹងរបបអាហាររបស់គ្រូបង្រៀន ឬក៏កងឈ្លប ឬក៏មេកងនៅក្នុងសហករណ៍របស់លោករស់នៅ ថាតើរបបអាហាររបស់ពួកគេយ៉ាងម៉េចដែរ? មានស្ថានភាពដូចប្រជាជនសាមញ្ញ ឬមួយក៏មានលក្ខណៈពិសេសខុសប្លែកពីប្រជាជនទូទៅ?

[១០:៥៤:៤៨]

**ឆ៖** មួបម្ហាខាងគ្រូ ខាងឈ្លប ខ្ញុំអត់ដឹង ដឹងតែខាងប្រជាពលរដ្ឋធ្វើស្រែដកស្ទូងជាមួយគ្នា ធម្មតាហូបជាមួយគ្នាធម្មតា។

**ស៖** សូមអរគុណ តើប្រជាជនដែលហូបបាយ ហូបជាមួយគ្នាហ្នឹងគេហូប ជំនាន់ហ្នឹងគេហូបបាយ ឬក៏គេហូបបបរ ឬក៏យ៉ាងម៉េចដែរ? ឬក៏ការហូបបាយជាប្រចាំរាល់ថ្ងៃតែម្ដង ឬក៏យ៉ាងម៉េច? សូមលោកជួយបំភ្លឺជូនអង្គជំនុំជម្រះ។

**ឆ៖** សហករណ៍ខ្ញុំបាយរាល់តែថ្ងៃ ប៉ុនតិចៗ មួយតុ ១០នាក់។

**ស៖** ក្នុងសហករណ៍របស់លោក លោកថាមានបាយហូបរាល់ថ្ងៃ។ តើការហូបរាល់ថ្ងៃរបស់លោកហ្នឹង អាចគ្រប់គ្រាន់នៅក្នុង -- គ្រប់គ្រាន់សម្រាប់ក្រុមលោកដែរឬទេ? សម្រាប់រូបផ្ទាល់ ឬក៏នៅក្នុងក្រុមទាំងមូល ទាំង១០នាក់ហ្នឹងដែរឬទេ?

**ឆ៖** មិនគ្រាន់ទេ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់មួយទៀត ទាក់ទងទៅនឹងផលស្រូវដែលប្រមូលបាន។ សួរថា តើផលស្រូវដែលប្រមូលបាន តាមបទពិសោធន៍របស់លោកនៅក្នុងអំឡុងពេលនុង លោកមានបានដឹងថាគេយកទៅណាដែរឬទេ? ហើយគេមានដែលចែកជូនប្រជាជនវិញ ដើម្បីចិញ្ចឹមជីវភាពទាំងអស់គ្នាដែរឬទេ?

[១០:៥៦:៣៤]

**ឆ៖** ពេលច្រូតកាត់ប្រមូលផល គេមានក្រុមគេវែងៗធំៗអីចឹង គេមានកងគេប្រមូលយកដាក់ទុក។ គេមិនបានចែកដល់ប្រជាពលរដ្ឋទេ។

**ស៖** តាមការសង្កេតរបស់លោក តើផលស្រូវដែលគេប្រមូលបានហ្នឹង លោកមានឃើញថា

ទំហំចំនួនស្រូវហ្នឹងច្រើន ឬក៏តិចនៅក្នុងអំឡុងពេលនុង?

**ឆ៖** ពេលកាលនុង ប្រមូលផលហើយ ខ្ញុំបានឃើញតាមក្រុម គេធ្វើទីលានក្រុមគេ ២០ម៉ែត្រ ទទឹង១០ម៉ែត្រ បណ្ដោយ២០ម៉ែត្រ ច្រើនណាស់ មិនៗតិចទេ ប៉ុន្តខ្ញុំមិនបានថ្លឹងថ្លែងមើលថាមានប៉ុន្មានៗ។

**ស៖** តើលោកមានដឹងឬទេ ផលស្រូវដែលគេប្រមូលបានហ្នឹង គេយកទៅណា?

**ឆ៖** ខ្ញុំអត់បានដឹង។

**ស៖** សូមអរគុណ ហើយខ្ញុំសូមបន្តសំណួរទៀត ទាក់ទងទៅនឹងកិច្ចប្រជុំវិញ។ មុននឹងបន្តិចហ្នឹង លោកបានលើកពាក់ព័ន្ធជាមួយនឹងកិច្ចប្រជុំ ប៉ុន្តែខ្ញុំសូមសួរលោកថា តើកិច្ចប្រជុំរបស់ខាងឃុំរបស់លោកហ្នឹង អាហ្នឹងគេធ្វើជាលក្ខណៈជាមួយឃុំពេញហ្នឹងតែម្ដង ឬក៏ជាកិច្ចប្រជុំសម្រាប់ក្រុមតូចៗតាមកងនីមួយៗ?

**ឆ៖** ជាញឹកញាប់ ប្រជុំតាមកង តាមក្រុមនីមួយៗ។

**ស៖** តើគេប្រជុំជារៀងរាល់ថ្ងៃ ឬក៏ជារៀងរាល់ខែ ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលដែលផ្លាស់ប្ដូរទីតាំងការងារ គឺប្រជុំ ឲ្យតែផ្លាស់ប្ដូរពីកន្លែងទៅកន្លែងមួយ គឺពេលនុងប្រជុំប្រាប់ ផ្លាស់ប្ដូរទៅទីនេះទីនោះ។

**ស៖** តើកិច្ចប្រជុំហ្នឹង គេធ្វើជារៀងរាល់ថ្ងៃ រាល់ខែ ឬក៏យ៉ាងម៉េច? សូមលោកជួយបញ្ជាក់កន្លែងហ្នឹងឡើងវិញបន្តិច។

**ឆ៖** គេប្រជុំមានផែនការការងារ គឺមិនរៀងរាល់ថ្ងៃទេ តែផែនការគេថាអង្គការដាក់ចុះមក គឺគេផែនការប្រជុំអ៊ីចឹង។

[១០:៥៩:៤០]

**ស៖** អ៊ីចឹង ខ្ញុំសូមបញ្ជាក់បន្តិច លោកថាទាល់តែមានផែនការដាក់ចុះ ទើបបានគេកោះហៅប្រជុំ។ អ៊ីចឹងមែនឬទេ?

**ឆ៖** មែន។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកបន្ថែមទៀតទាក់ទងនឹង អ្នក--

**ប្រធានអង្គជំនុំ៖**

បើកៗក្បាលមីក្រូហ្វូន។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំសូមបញ្ជាក់លោកបន្ថែមទៀត ពាក់ព័ន្ធជាមួយនឹងអ្នកចូលរួមប្រជុំ។ តើនរណាគេជាអ្នកចូលរួមរាល់កិច្ចប្រជុំម្ដងៗ?

**លោក សៅ ប៊ាន៖**

**ឆ៖** ពេលប្រជុំម្ដងៗ ប្រជុំធំបន្តិចទៅ មេកង ប្រជុំតូចទេ តាមមេក្រុម។ មេក្រុមទៅទទួលផែនការពីមេកង។

**ស៖** សូមអរគុណ។ តើលោកមានដែលចូលរួមកិច្ចប្រជុំធំអីដែរឬទេ? ដូចជាការប្រជុំធ្វើមីទ្ទិងអី ថ្នាក់ៗឃុំតែម្ដងណា៎ះ លោកមានដែលធ្លាប់ចូលរួមកិច្ចប្រជុំធំបែបហ្នឹងដែរឬទេ?

**ឆ៖** ពេលៗប្រជុំធំ ខ្ញុំយូរៗចូលបានម្ដងដែរ។ អាហ្នឹងប្រជុំភូមិហើយហ្នឹង ដូចថាមួយកងហ្នឹងប្រជុំមួយកង។ បើមីទ្ទិង ខ្ញុំអត់ដែលបានទេ។

**ស៖** ចុះក្នុងអំឡុងពេលដែលលោករស់នៅក្នុងស្រុកត្រាំកក់ ៣ឆ្នាំ ៨ខែហ្នឹង តើលោកមានដែលឃើញថ្នាក់ដឹកនាំណាមួយគេចុះទៅសហករណ៍របស់លោក ដើម្បីសួរសុខទុក្ខប្រជាជនដែរឬទេ?

**ឆ៖** អត់ៗដែលឃើញទេ។

[១១:០១:៥២]

**ស៖** សូមអរគុណ ខ្ញុំសូមបន្តសំណួរទៀត។ ទាក់ទងទៅនឹងមុននឹងបន្តិចហ្នឹង លោកបានលើកឡើងអំពីរបបអាហារដែលនិយាយ លោកលើកឡើងថា "ដាច់អាហារមិនប៉ាន ប្រជាជន -- សួរថាប្រជាជនប៉ានរអ៊ូរទាំ ឬក៏ទេ?" ហើយលោកបានលើកឡើងថា "មិនប៉ានរអ៊ូទេ តែនិយាយដល់រឿងហ្នឹងគឺនឹងមានការបាត់ខ្លួនហើយ"។ អ៊ីចឹងខ្ញុំចង់សួរថាតើទាក់ទងទៅនឹងការបាត់ខ្លួននេះ លោកដឹងតែខ្លួនឯងតែម្នាក់ឯង ឬក៏មានគេជិតខាងរបស់លោកដឹងឮរឿងបាត់ខ្លួននឹងដែរ ឬក៏យ៉ាងម៉េច? សូមលោកជួយបំភ្លឺជូនអង្គជំនុំជម្រះបន្តិច។

**ឆ៖** ពេលបាត់ខ្លួនរហូត ដឹងថាបាត់ពីក្រុម ពីកងហើយ រឹតតែមិនប៉ាននិយាយទៅទៀត ខ្លាច។

**ស៖** សូមអរគុណ ខ្ញុំសូមធ្វើការបញ្ជាក់ឡើងវិញបន្តិច។ ថាតើនៅពេលដែលមានការបាត់ខ្លួនហ្នឹងអ្នកដែលដឹងរឿង រឿងនៃការបាត់ខ្លួននេះ គឺអ្នកជិតខាងរបស់លោក ក៏ដូចជាប្រជាជននៅក្នុងសហករណ៍ត្រាំកក់ទាំងមូលហ្នឹង គេដឹងឮរឿងហ្នឹងដូចគ្នាឬក៏យ៉ាងម៉េច?

**ឆ៖** អាហ្នឹងអត់បានដឹងទេ ខ្ញុំអត់បានដឹងទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សូមអរគុណ។ ពាក់ព័ន្ធជាមួយនឹងការភ័យខ្លាចវិញដូចរូបលោកផ្ទាល់លោកលើកឡើងថាឲ្យតែរឿងអីមួយអ៊ីចឹង គឺតែងតែមានការភ័យខ្លាច សូម្បីតែការហូបចុកក៏មិនហ៊ាននិយាយ គឺតែងតែមានការភ័យខ្លាច ដោយសារមូលហេតុនៃការបាត់ខ្លួន។ អ៊ីចឹងខ្ញុំចង់សួរថាអ្នកដទៃហ្នឹងក៏គេមានការភ័យខ្លាចដូចរូបលោកដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** រឿងពេលដែលបាត់ខ្លួនម្ដងៗក្នុងក្រុម ក្នុងខ្លួនខ្ញុំផ្ទាល់ ក្នុងចិត្តខ្ញុំផ្ទាល់ ខ្ញុំខ្លាចអត់ហ៊ាននិយាយថាអីៗ អត់។ ហើយអ្នកដទៃប្រ--

**ស៖** សូមៗលោកបើកក្បាលមីក្រូ ហើយនិងសូមឆ្លើយបំភ្លឺកន្លែងចំណុចនេះឡើងវិញ ព្រោះដោយសារអំមិញខ្ញុំឮសំឡេងលោកនិយាយក្រៅក្បាលមីក្រូ។

**ឆ៖** ពេលដែលបាត់ខ្លួនក្នុងក្រុមម្នាក់អ៊ីចឹងទៅ ខ្ញុំរឹតតែភ័យឡើង ខ្លាចឡើង អត់ហ៊ាននិយាយអីទាំងអស់ ខ្លាចថ្ងៃណាមួយ ដល់វេនខ្ញុំ។

[១១:០៥:១១]

**ស៖** ចុះចំពោះអ្នកដទៃ អ្នកជិតខាងរបស់លោក តើគេដូចលោក ភ័យខ្លាចដូចរូបលោកដែរ អំពីការបាត់ខ្លួនហ្នឹងដែរឬក៏យ៉ាងម៉េច?

**ឆ៖** បើនៅក្នុងក្រុមជាមួយគ្នាផ្ទាល់ មានអ្នកខ្លះ "យី! បាត់ម្នាក់ហ្នឹងទៅណា មិនឃើញមក" មាននិយាយតែប៉ុណ្ណឹង។ សួរគ្នាឯងផ្ទាល់ដែលទុកចិត្ត។

**ស៖** តាមការសង្កេតរបស់លោក តើស្ថានភាពពេលដែលពួកគាត់លើកនិយាយជុំគ្នាជាមួយលោកហ្នឹង សួរថាតើអារម្មណ៍របស់គាត់ហ្នឹងមានការភ័យខ្លាចដូចរូបលោកដែរ ឬក៏គ្រាន់តែនិយាយចោលទេ?

**ឆ៖** តាមអារម្មណ៍ខ្លាចដូចខ្ញុំដែរ។

**ស៖** សូមអរគុណ។ នាងខ្ញុំសូមសួរទាក់ទងទៅនឹងមន្ទីរសន្តិសុខបន្តិច។ សួរថាតើលោកនៅក្នុងសហករណ៍របស់លោកហ្នឹង មានស្គាល់មន្ទីរសន្តិសុខណាដែរឬទេ?

**ឆ៖** មន្ទីរសន្តិសុខ ខ្ញុំអត់បានស្គាល់ទេ ព្រោះគេលាក់ណាស់។ យើងអត់មានសិទ្ធិស្គាល់បាន។

**ស៖** សូមអរគុណ។ ចុះលោកស្គាល់មន្ទីរសន្តិសុខក្រាំងតាចាន់ដែរឬទេ?

**ឆ៖** ពេលក្រោយនេះហើយបានខ្ញុំស្គាល់ ហើយខ្ញុំបានទៅដល់ទៀត ពេលក្រោយ៧៩នេះ។

**ស៖** សូមអរគុណ។ ចុះនៅក្នុងអំឡុងពេលដែលលោករស់នៅ៣ឆ្នាំ៨ខែ ក្នុងសហករណ៍ត្រាំកក់

ហ្នឹង តើលោកមានដែលប្រទះឃើញរណ្ដៅសាកសពអីដែរឬទេ នៅម្ដុំជិតៗតំបន់លោករស់នៅនោះ?

[១១:០៧:១៣]

**ឆ៖** ខ្ញុំអត់បានឃើញទេ។

**ស៖** សូមអរគុណ។ នាងខ្ញុំសូមសួរសំណួរទាក់ទងទៅនឹងផ្ទះសម្បែងប្រជាជនវិញ។ នៅក្នុងអំឡុងពេល៣ឆ្នាំ៨ខែហ្នឹង តើនៅក្នុងសហករណ៍របស់លោកហ្នឹងគេមានចែកផ្ទះឲ្យប្រជាជនរស់នៅ។ តើការចែកផ្ទះឲ្យប្រជាជនរស់នៅហ្នឹង គឺចែកដើម្បីឲ្យទៅជាកម្មសិទ្ធិរបស់ប្រជាជនមួយៗ ឬក៏គ្រាន់តែឲ្យស្នាក់នៅបណ្ដោះអាសន្នទេ?

**ឆ៖** ស្នាក់នៅបណ្ដោះអាសន្ន អត់មានកម្មសិទ្ធិ។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណ។ នាងខ្ញុំសូមចប់សំណួរត្រឹមនេះ ហើយនិងសូមផ្ទេរវេទិកានេះ ជូនទៅលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ដែលជាសហមេធាវីនាំមុខអន្តរជាតិ ដើម្បីតាំងសំណួរបន្ត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរខ្លីៗទេ លោកសាក្សី។ ខ្ញុំចង់ដឹងថាតើមានឈ្លបដែរឬទេ នៅក្នុងសហករណ៍របស់លោក?

**លោក សៅ ប៊ាន៖**

**ឆ៖** ឈ្លបមានតែក្នុងឃុំទាំងមូល មានឈ្លបមួយក្រុម។

**ស៖** តើលោកអាចពន្យល់អំពីតួនាទីរបស់ឈ្លបបានទេ?

**ឆ៖** តួនាទីរបស់ឈ្លប ខ្ញុំធ្លាប់ឃើញ ដើរតែស៊ើបអង្កេតតាមផ្ទះ តាមក្រុម។

[១១:០៩:៤០]

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺសកម្មភាព<ចម្បង>របស់ឈ្លបហ្នឹង គឺកម្រិតត្រឹមតែការ<ឃ្លាំមើលតាម>ផ្ទះសម្បែង គឺមិន<ឃ្លាំមើលសកម្មភាព>នៅតាមស្រែចម្ការទេ អ៊ីចឹងមែនទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ មែន។

**ស៖** <តើលោកដឹងថា ឈ្លបហ្នឹងឃ្លាំមើលអ្វីខ្លះដែរ?> លោកនិយា<យ>ថាគាត់ឃ្លាំមើលតាមផ្ទះហ្នឹង គាត់ឃ្លាំមើលអី<ឲ្យប្រាកដ>ដែរ?

**ឆ៖** ពេលដែលគាត់ឃ្លាំមើល ៗតាមផ្ទះ តាមតូបនីមួយៗហ្នឹងចាំមើលអ្នកលួចចំណីចំណុកអីហូបនៅពេលយប់។

**ស៖** សូមអរគុណ។ លោកនិយាយអំពីឈ្លបមួយក្រុម អ៊ីចឹងខ្ញុំចង់ដឹងថា មួយក្រុមហ្នឹងមានឈ្លបប៉ុន្មាននាក់? ហើយឈ្លបទាំងអស់នោះមានអាយុប៉ុន្មានដែរ?

**ឆ៖** ឈ្លបទាំងអស់ខ្ញុំមិនដឹងមានប៉ុន្មានទេ ព្រោះខ្ញុំខ្លាចណាស់កន្លែងណាដែលមានឈ្លប អាយុក៏ខ្ញុំអត់ដឹង។

**ស៖** តើលោកឃើញឈ្លបទាំងអស់ហ្នឹងជាទៀងទាត់ ឬក៏ឃើញគ្រាន់តែម្ដងម្កាល ឬក៏ក្នុងកាលៈទេសៈពិសេសណាមួយទេ?

**ឆ៖** ខ្ញុំឃើញម្ដងម្កាលព្រោះខ្ញុំការងារជាប់នៅការដ្ឋានខាងក្រៅទាំងអស់។

**ស៖** សូមអរគុណ។ តើឈ្លបទាំងអស់នោះ មានកាន់អាវុធទេ?

**ឆ៖** ខ្ញុំឃើញម្ដងៗ មាន។

**ស៖** គាត់កាន់អាវុធហ្នឹង អាវុធប្រភេទណាដែរ?

**ឆ៖** ខ្ញុំអត់បានស្គាល់ទេអាវុធ មិនដឹងប្រភេទណាទេ។

**ស៖** ខ្ញុំចង់ឲ្យលោកនិយាយឲ្យច្បាស់បន្តិច។ ចុះលោក អាវុធហ្នឹងមានន័យថាជាកាំភ្លើងឬក៏ជាអ្វីផ្សេង?

**ឆ៖** កាំភ្លើងបាទ កាំភ្លើង។

**ស៖** លោកប្រធាន ខ្ញុំអត់ទទួលបានការបកប្រែចម្លើយអម្បាញ់មិញនេះទេ ខ្ញុំមិនដឹងថាតើអង់គ្លេសមានបកទេ ប៉ុន្តែភាសាបារាំងខ្ញុំស្ដាប់អត់ឮទេ។ តើខ្ញុំត្រូវសួរឡើងវិញ ឬក៏យ៉ាងម៉េចលោកប្រធាន?

[១១:១៣:០០]

**ប្រធានអង្គជំនុំ៖**

សាក្សីសូមឆ្លើយសំណួរចុងក្រោយម្ដងទៀត។ បាទ មិនទាន់ អត់ទាន់ ក្បាលមេក្រូហ្វូនអត់ទាន់

ប្រតិបត្តិការទេបាទ។

**លោក សៅ ប៉ាន៖**

**ឆ៖** បាទ ខ្ញុំឃើញឈ្លបម្តងៗកាន់កាំភ្លើងនៅនឹងដៃ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងការឆ្លើយអម្បាញ់មិញនេះ ខ្ញុំស្តាប់អត់ឮការបកប្រែទេ។ ខ្ញុំចង់សួរឲ្យបានច្បាស់ថា កាន់អាវុធហ្នឹង អាវុធប្រភេទណា? ជាកាំភ្លើង ឬក៏ជាអ្វី?

**ឆ៖** បាទ ជាកាំភ្លើង។ ប្រភេទ ខ្ញុំអត់ស្គាល់។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរចុងក្រោយ តើលោកដឹងទេថានៅសម័យនោះឈ្លប គេរើសឈ្លបទាំងអស់នោះតាមរបៀបណាដែរ?

**ឆ៖** ខ្ញុំអត់បានដឹងថារើសតាមរបៀបណាទេ។

**ស៖** បាទ សូមអរគុណ។ សំណួរចុងក្រោយមួយទៀត។ កាលពីម្សិលមិញ ខ្ញុំបានឮសក្ខីកម្មរបស់សាក្សីមួយរូបដែលនិយាយថា៖ "ឈ្លបមានតួនាទីលបស្តាប់គូស្រករដែលទើបតែរៀបការថ្មី ថាតើពួកគាត់ចុះដំណោកនឹងគ្នាអត់"។ អ៊ីចឹងតើលោកមានធ្លាប់ឃើញរបៀបហ្នឹងទេ ថាឈ្លបហ្នឹងគឺតួនាទីគាត់<>លបស្តាប់នៅក្រោមផ្ទះដើម្បីចង់ដឹងថាគូស្រករចុះដំណេកនឹងគ្នាឬក៏អត់?

**ឆ៖** ខ្ញុំអត់បានឃើញទេ ខ្ញុំអត់បានឮទេ។

[១១:១៥:០៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ លោកសាក្សី។ លោកប្រធាន សូមអរគុណ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក -- ក្រុមមេធាវីការពារក្តី ដំបូងនេះ សូមផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១១:១៥:៤២]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមិនមានសំណួរច្រើនប៉ុន្មានទេ មានតិចតួចដែរទេ។ សំណួរមួយ គឺពាក់ព័ន្ធទៅនឹងអ្វីដែលលោកទើបតែនិយាយពី២០នាទីមុននេះ ខ្ញុំយល់មិនច្រឡំ គឺលោកបាន<ឮអំពី> ក្រាំងតាចាន់ ក្រោយឆ្នាំ១៩៧៩ <ប៉ុណ្ណោះ>។ អ៊ីចឹងមែនទេ?

**<លោក សៅ ប៊ាន៖>**

**ឆ៖** អ៊ីចឹងមែន។

**ស៖** ពីមុននេះ <លោកត្រូវបានចោទ>សួរអំពីបងប្រុសរបស់លោក<> ដែលឈ្លប<នាំ>ខ្លួន យកទៅ។ តើវាត្រឹមត្រូវទេបើខ្ញុំនិយាយថា លោកបានដឹង<ពីកន្លែងដែល>ប្រុសរបស់លោក<ត្រូវបាន គេនាំខ្លួនយកទៅ> គឺនៅក្រោយឆ្នាំ១៩៧៩ទេ? ឬក៏លោកអាចដឹងថាមានអ្វីកើតឡើងចំពោះបងប្រុស របស់លោកនៅមុនឆ្នាំ១៩៧៩ដែរទេ?

**ឆ៖** ពេលមុន១៩៧៩ គ្មានអីកើតឡើងទេ គឺបងប្រុសខ្ញុំមួយហ្នឹង នៅក្នុងនុងលន់ នល់ ឯណោះ នោះ។ សុំសួរម្តងទៀតបាទ សូមអញ្ជើញសួរម្តងទៀត។

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ តាំងសំណួរលោកម្តងទៀត ចំពោះសាក្សី។ សាក្សីស្តាប់សំណួរលោកមិន យល់ទេ ឬក៏គាត់ភ្លេចហើយអំមិញសំណួរដែលលោកសួរ។ បាទសូមអញ្ជើញ!

[១១:១៧:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទលោកប្រធាន ខ្ញុំនឹងព្យាយាមសួរតាមវិធីផ្សេង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបានឆ្លើយពីព្រឹកមិញថា លោកបានឮឈ្មោះក្រាំងតាចាន់ ឮឈ្មោះមន្ទីរ សន្តិសុខក្រាំងតាចាន់គឺនៅក្រោយឆ្នាំ១៩៧៩។ ការណ៍ដែលនិយាយដូច្នេះ គឺខ្ញុំចង់សួរអំពីបងប្រុសរបស់ លោក។ នៅពេលណាពិតប្រាកដនោះ ដែលលោកបានដឹងថា<គេបាននាំ>បងប្រុសរបស់លោកយកទៅ <ទីណាដែរ>?

**ឆ៖** ក្រោយពេលដែលចាប់បងប្រុសខ្ញុំទៅនោះ បានដឹងពីបងប្អូនក្នុងគ្រួសារហ្នឹងដែរ។

**ស៖** លោកសាក្សី <តើអ្វីដែលប្រាកដ ដែល>លោកបានដឹង<ថាគេនាំយក>បងប្រុសរបស់

លោក<ទៅទីណាដែរ>?

**ឆ៖** បាទអត់ដឹង។

**ស៖** ដូច្នេះចម្លើយរបស់លោក<ឥឡូវនេះ គឺលោក>ឆ្លើយថា លោកមិនដឹងទេចន្លោះពីឆ្នាំ៧៥ ដល់៧៩ មិនដឹងថាគេ<យក>បងប្រុសរបស់លោក<ទៅទី>ណាទេ។ អ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១១:១៩:៣៧]

**ឆ៖** បាទត្រឹមត្រូវ។

**ស៖** អ្នកណាប្រាប់លោក ឬក៏លោកដឹងដោយរបៀបណា ដែលថាបងប្រុសរបស់លោកអាចត្រូវបានគេនាំខ្លួនយកទៅក្រាំងតាចាន់<? បើខ្ញុំមិនច្រឡំទេ> លោកឆ្លើយថា <ប្រហែលជា>លោកឮ<រឿងហ្នឹងនៅ>ក្រោយឆ្នាំ១៩៧៩ <>។ តើលោកដឹង<រឿងហ្នឹងដោយរបៀបណា ឬក៏លោកមិនបានដឹងទេ>?

**ឆ៖** កាលក្នុងអំឡុង ៣ឆ្នាំ ៨ខែហ្នឹង ខ្ញុំដឹងដោយសារអ្នកឃ្វាលគោក្បែរហ្នឹង គេថាកុំទៅបៀតៗ ខ្ញុំឃ្វាលគោដែរ ខ្ញុំមើលគោដែរ គេថាកុំទៅបៀតៗ កន្លែងហ្នឹងមិនបានទេ មន្ទីរឃុំឃាំងក្រាំងតាចាន់ហ្នឹង ទៅមិនបានទេ។ ពេលអំឡុងក្នុង ៣ឆ្នាំ ៨ខែ។ ដល់ពេលដែលក្រោយ ៧៩ មកអ៊ីចឹងទាំងអស់គ្នាបាននាំគ្នាទៅពិនិត្យមើលនៅក្រាំងតាចាន់ ទាំងអ្នកបាត់ប្ដី ទាំងអ្នកបាត់កូន បាត់បង បាត់ប្អូនហ្នឹង នាំគ្នាទៅដើរមើលនៅទីក្រាំងតាចាន់ហ្នឹង។ ហើយក្រោយមកទៀតហ្នឹង មានទៅបង្សុកូល បាំងអី រំឭកនៅទីនោះ។

**ស៖** <តើប្រហែលជា>លោកមានបានឃើញឈ្មោះបងប្រុសរបស់លោកនៅក្នុងឯកសារណាមួយដែលគេបានរក ឃើញក្រោយឆ្នាំ១៩៧៩ <> ឬក៏លោកមិនបាន<ឃើញទេ>?

**ឆ៖** បាទអត់ឃើញទេ មិនដែលបានទាក់ទងដើរសួររកឈ្មោះហ្នឹងផង។

**ស៖** ដូច្នេះសរុបមកវិញគឺថា ត្រឹមត្រូវទេដែលថាជាការពិតនោះគឺមិនដឹងថាបងប្រុសរបស់លោកត្រូវគេសម្លាប់នៅក្រាំងតាចាន់ ឬក៏អត់នោះទេ។ អ៊ីចឹងទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** សូមអរគុណលោកសាក្សី។ សំណួរមួយទៀតគឺសំណួរ ពាក់ព័ន្ធទៅនឹង<ពាក្យ "បាត់ខ្លួន">។ លោកប្រើប្រាស់ជាញឹកញាប់ព្រឹកមិញនេះ។ តើលោកចង់និយាយថា បាននិយាយថាយ៉ាងម៉េច ឬក៏មានន័យថាម៉េចចំពោះពាក្យថាបាត់ខ្លួននេះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ធ៖** បាត់ខ្លួននេះ ខ្ញុំមិនដឹងថាចង់និយាយថាម៉េចទេ ស្រាប់តែបាត់ៗរហូតទៅ មិនដឹងយកទៅទីណា ទៅទិសណា។

**ស៖** ខ្ញុំយល់ចម្លើយហ្នឹងហើយ ប៉ុន្តែប្រសិនណាអ្នកណាម្នាក់ចេញទៅណាបាត់ពីសហករណ៍ ហើយអត់ត្រឡប់មកវិញ ប្រហែលជាគេបញ្ជូនបុគ្គលនោះទៅសហករណ៍ផ្សេង ឬក៏ទៅភូមិភាគផ្សេង។ <ប៉ុន្តែ>លោក<មិនបានដឹង>រឿងហ្នឹងទេ?

[១១:២២:៤៩]

**ធ៖** ខ្ញុំអត់បានជ្រាបទេ រឿងបញ្ហាដែលគេបាត់ខ្លួនទៅយកទៅនេះ យកទៅនោះ ខ្ញុំអត់ដឹងទេ។ ដឹងថាបាត់ខ្លួនចេញពីក្រុមពីកង។

**ស៖** ដូច្នេះពាក្យថាបាត់ខ្លួនដែលលោកប្រើហ្នឹងគឺៗគ្រាន់តែមានន័យថា អ្នកណាម្នាក់បាត់ពីកន្លែងហ្នឹងទៅ ហើយអត់ឃើញត្រឡប់មកវិញ។ អ៊ីចឹងមែនទេ?

**ធ៖** បាទមែន។

**ស៖** សូមអរគុណ។ ពីខាងដើមនោះ លោកនិយាយអំពីមេកងរបស់លោក មេក្រុមរបស់លោក ហើយជួនកាលនិយាយអំពីកម្មាភិបាលជាថ្នាក់ដឹកនាំផ្សេងទៀត។ បើខ្ញុំយល់មិនច្រឡំទេ គឺចម្លើយរបស់លោកពាក់ព័ន្ធទៅនឹងប្រធាន គឺថាមិនមែនជាបុរសម្នាក់ដែលមានសន្តានចិត្តល្អទេ តើត្រូវទេបើខ្ញុំនិយាយអ៊ីចឹង?

**ធ៖** បាទ ត្រូវ។

**ស៖** ខ្ញុំសូមបង្ហាញពាក្យពេចន៍ខ្លះទៅលោក ចង់ដឹងថាតើពាក្យពេចន៍ទាំងនេះ វាអាចរៀបរាប់ទៅលើឥរិយាបថៗរបស់ប្រធានកងលោក មកចំពោះលោក និងសមាជិកក្រុមដទៃទៀតទេ ដូចដែលលោកបានរៀបរាប់អំពីៗឥរិយាបថរបស់មេកងលោក។ ខ្ញុំសូមផ្តល់ពាក្យ ប្រាំមួយ ប្រាំពីរពាក្យ។ ថាតើពាក្យនេះបញ្ជាក់ទៅលើឥរិយាបថរបស់មេកងរបស់លោកដែរឬក៏អត់នោះ លោកយល់ត្រឹមនេះសិនលោកយល់ទេ?

**ធ៖** ខ្ញុំបាទ អត់បានយល់ទេ។

**ស៖** លោកប្រធានខ្ញុំសូម ខ្ញុំមិនដាក់ឯកសារនេះក្នុងអ៊ីនធឺហ្វេសទេ ប៉ុន្តែឯកសារហ្នឹងគេដឹងគ្រប់គ្នាហើយ ភាគីទាំងអស់ដឹងហើយ គឺទំព័រ<មួយ>ដែលចេញពីទស្សនាវដ្តីទង់បដិវត្ត ចុះខែកក្កដា ១៩៧៨ <គឺឯកសារ E3/746 អង់គ្លេស ERN 00428305>, ខ្មែរ ERN <00064504>, បារាំង

<00611886។ ឥឡូវនេះនៅក្នុង> ទំព័រជាភាសាអង់គ្លេស <"ទង់បដិវត្ត"> គឺទំព័រ១៧។ ខ្ញុំសូមចូលទៅត្រង់កថាខណ្ឌ គឺកថាខណ្ឌមុនកថាខណ្ឌ៥ ដែលមាននិយាយអំពីឥរិយាបថ ហើយខ្ញុំចង់ប្រើប្រាស់ពាក្យនេះ និងសួរទៅសាក្សី ថាតើគាត់នៅចាំអំពីឥរិយាបថរបស់មេកងគាត់ដែរ ឬក៏អត់។

[១១:២៦:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីអន្តរជាតិ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

ជាគោលការណ៍ ខ្ញុំជំទាស់ទៅនឹងការប្រើឯកសារនេះ។ យើងព្យាយាមធ្វើយ៉ាងណាឲ្យភាគីទាំងអស់ហ្នឹង គោរពនីតិវិធីដូចគ្នា ហើយនិងដាក់ឯកសារដែលចង់ប្រើទៅក្នុងលើអ៊ីនធឺហ្វេស។ ម្សិលមិញយើងធ្វើការលើកលែងមួយហើយ ឬក៏ម្សិលម៉្ងៃទេ <ខ្ញុំចាំមិនច្បាស់ដែរ>។ អ៊ីចឹង បើយើងនៅតែលើកលែងរហូតហ្នឹង អ៊ីចឹង គោលការណ៍លែងមានខ្លឹមសារអីទៀតហើយ។ អ៊ីចឹង ដើម្បីការពារគោលការណ៍នេះ ខ្ញុំសូមជំទាស់មិនឲ្យប្រើឯកសារនេះ ហើយសូមឲ្យអង្គជំនុំជម្រះសម្រេចទៅតាមការយល់ឃើញរបស់ខ្លួន។

[១១:២៧:០៦]

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ពេលខ្លះនៅពេលដែលយើងស្ដាប់ទៅលើសាក្សីនិយាយអំពីបញ្ហាជាក់លាក់ណាមួយ យើងគិតថា វាអាចមានសំណួរដែលអាចតាំងទៅកាន់សាក្សីបាន <ហើយវាបានលេចចេញជាសំណួរនៅពេលដែលខ្ញុំតាំងសំណួរទៅកាន់សាក្សីនេះ>។ ខ្ញុំមិនមានចេតនាធ្វើឲ្យអ្នកណាម្នាក់ភ្ញាក់ផ្អើលនោះទេ<។ ខ្ញុំរីករាយនឹងបញ្ចប់ក្នុងពេលនេះ ហើយបន្តសំណួរបន្ទាប់ពីពេលសម្រាកបាន។> ហើយឯកសារនេះ ឯកសារបានពិភាក្សាគ្នាយ៉ាងជ្រាលជ្រៅហើយ គឺថាគ្មានភាគីណាមួយមិនបានដឹងអំពីឯកសារនេះទេ។ <វាជាសំណួរមួយដ៏ពិបាក ហើយ>វាអាចមានបញ្ហាទៅនឹងការតាំងសំណួរ ខ្ញុំយល់។ អ្វីដែលខ្ញុំចង់បាននោះ គឺ<ខ្ញុំព្យាយាមធ្វើនោះ គឺចង់ឲ្យមើលឃើញ ឬក៏អាច>កំណត់អំពីអត្តចរិតរបស់មេក្រុម <ឬ> មេកងរបស់គាត់<ហ្នឹង ថាតើមាន>ឥរិយាបថមិនល្អ ឥរិយាបថអាក្រក់<ហ្នឹងជាអត្តចរិតរបស់បុគ្គលផ្ទាល់ ឬក៏អាចថាធ្វើតាមមាគ៌ាបក្ស>។ អ៊ីចឹងអ្វីដែលសំខាន់សម្រាប់ឯកសារនេះ គឺថាវាមាន

របៀប មានស្ទីល ឬក៏មានឥរិយាបថដែលគេរៀបរាប់អំពីពាក្យពេចន៍ទាំងអស់នេះ។ ដូច្នេះ ខ្ញុំចង់ដឹងមើល ថាតើសាក្សីរូបនេះ គាត់អាចនៅដឹងថាមេក្រុម <ឬ>មេកងរបស់គាត់ វាមានឥរិយាបថពាក់ព័ន្ធទៅនឹងពាក្យទាំងនេះទេ។ <ខ្ញុំមិនគិតថា វាមានបញ្ហានៅក្នុងការតាំងសំណួរនេះទេ។>

[១១:២៨:៣២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ត្រាវិស ហ្សារ៖**

សូមអរគុណលោកប្រធាន។ <>យ៉ាងហោចណាស់ ខ្ញុំគិតថាវាពិបាកនឹង<កំណត់ថា តើយើងនឹងមាន>ការបដិសេធ<ចំពោះ>ឯកសារ <ឬក៏ការតាំងសំណួរនោះទេ ដោយមិនបានពេលវេលា> យ៉ាងហោចណាស់ <> ពីរបីនាទី ដើម្បីពិនិត្យមើលឯកសារនេះដែរ។ <ដូច្នេះ វាជាសំណើសុំផ្តល់នូវអត្តសញ្ញាណឯកសារ។> បើសិនលោក កូប៉េ ចង់<បន្តការ>តាំងសំណួរផ្សេងទៀត ខ្ញុំសុំ<ឱ្យលោកផ្តល់>លេខឯកសារដែរអម្បាញ់មិញ<ម្តងទៀត ដោយសារខ្ញុំតាមមិនទាន់ទេ។>។ ហើយបើគាត់ចង់សួរបន្ទាប់ពីសម្រាកបាយថ្ងៃត្រង់ហើយ សូមបញ្ជាក់លេខឯកសារផង ដើម្បីកំណត់ថាយើងខ្ញុំនឹងត្រូវជំទាស់ ឬក៏អត់។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោក វ៉ិចទ័រ! ហើយទី១ បញ្ជាក់អត្តសញ្ញាណឯកសារម្តងទៀត ព្រោះដូចភាពមិនច្បាស់លាស់ រវាងភាគីដែលពាក់ព័ន្ធហ្នឹង គឺសូមអានយឺតៗ ហើយនិងអាចអានពីរដង ដូចយើងបានជម្រាបលោកម្តងហើយបញ្ហាហ្នឹង។ ហើយទី២ បើមានសំណួរអីផ្សេងទៀត សួរសំណួរហ្នឹងសិនទៅ ហើយចាំមើលភាគីគេពិនិត្យមើលលើឯកសារដែលលោកមានបំណងក្នុងការផ្អែកជាសំអាងក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះ នៅអំឡុងពេលអាហារថ្ងៃត្រង់ជាមុនសិន។ ហើយអង្គជំនុំជម្រះនឹងពិនិត្យសម្រេចលើបញ្ហានេះ នៅបន្ទាប់ពីចូលចាប់ផ្តើមក្រោយពេលអាហារថ្ងៃត្រង់។ បាទនៅរសៀលនេះ។

**លោក វ៉ិចទ័រ កូប៉េះ៖**

បាទ លោកប្រធាន គឺជាទស្សនាវដ្តីទង់បដិវត្តន៍ ខែកក្កដា ឆ្នាំ១៩៧៨ គឺ E3/746, ERN ជាភាសាអង់គ្លេស <00428305>, ERN ជាភាសាបារាំង 00611886, ERN ខ្មែរ 0064504 *(ស៊ី*

*ក)*។ ហើយពាក្យដែលខ្ញុំចង់ប្រើនោះគឺ ការដែលខ្ញុំប្រើឯកសារហ្នឹង ខ្ញុំចង់បានពាក្យខ្មែរឲ្យចំៗតែម្តង។

**ប្រធានអង្គជំនុំ៖**

លោកប៉ុណ្ណឹងបានហើយ លោកមានសំណួរអីសួរផ្សេងពីហ្នឹងទេ ចំពោះអ្វីដែលត្រូវដោះស្រាយបញ្ហានេះអង្គជំនុំជម្រះចាំទុកពេលវេលាឲ្យភាគីម្ខាងទៀតដើម្បីពិនិត្យឯកសារនេះ ហើយចូលមកវិញថាគាត់ជំទាស់ឬមិនជំទាស់។ ពេលនោះអង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះឲ្យបានដាច់ស្រេចតែម្តង។ អំមិញមានការជំទាស់ច្បាស់លាស់ហើយពីក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែនៅសហព្រះរាជអាជ្ញាមួយទៀត ភាគីមួយដែរ។ ហើយបើមានលោកមានសំណួរអីផ្សេងពីនេះ សួរទៅហើយសំណួរនេះទុកដោះស្រាយនៅពេលដែលអង្គជំនុំជម្រះសម្រេចរួចក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិ -- សហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹងគឺសម្រេចថាជំទាស់ ឬមិនជំទាស់ក្រោយពីគាត់ពិនិត្យឯកសារនៅក្នុងអំឡុងពេលសម្រាកអាហារថ្ងៃត្រង់នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចៅក្រម ហ្វេនស៍។

[១១:៣១:៥០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សំណួរមួយពាប់ព័ន្ធទៅនឹងឯកសារនេះ បើខ្ញុំយល់មិនច្រឡំទេ សំណួរគឺពាក់ព័ន្ធទៅនឹងអត្តចរិតរបស់បុគ្គលម្នាក់។ <តើហេតុអ្វីបានជា>លោកមិន<>សួរសំណួរ<បើក ដោយឲ្យសាក្សីពិពណ៌នាអំពីបុគ្គលនោះទៅ? ហេតុអ្វីបានជាយើងត្រូវ>យកពាក្យនៅក្នុងឯកសារ យកមកបញ្ចុកចូលមាត់សាក្សី <បែបនេះ>?

**លោក វ៉ិចទ័រ កូប៉េ៖**

<សំណួររបស់ខ្ញុំ គឺមានមូលដ្ឋានច្បាប់មួយ> ដោយសារវាមានលក្ខណៈខុសគ្នា ឧទាហរណ៍និយាយអំពី<គំនិតរបស់>ថ្នាក់ដឹកនាំកំពូល<នៃបក្សកុម្មុយនីស្តកម្ពុជា ដែល>គេនិយាយអំពីជំហរដាក់លាក់<> ហើយថាតើកម្មាភិបាលមូលដ្ឋាននោះ ថ្នាក់ក្រោមនោះអនុវត្តដោយរបៀបណា <ហើយវាមានភាពខុសគ្នាចំពោះបញ្ហានេះ។> នេះគឺជាទឡ្ហីករផ្នែកច្បាប់<ដែលគួរឲ្យចាប់អារម្មណ៍មួយ>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្ទបកប្រែ និងខ្ទបកប្រែបន្ត។*

ពាក្យដែលប្រើនៅទីនេះគឺជាពាក្យមួយដែលគេប្រើនៅជំនាន់នោះជាក់លាក់តែម្តង។ អ៊ីចឹងឯងបានជាខ្ញុំចង់យកពាក្យខ្មែរឲ្យចំៗតែម្តងយកមកសួរសាក្សីរូបនេះ ដើម្បីឲ្យយើងទទួលបាននូវការរៀបរាប់បានកៀកទៅនឹងការពិតអំពីអត្តចរិតរបស់ប្រធានក្រុម របស់មេក្រុម <និង> មេកង <គឺជាមនុស្សដែលអាក្រក់>។ ហេតុដូច្នេះឯង បានជាខ្ញុំចង់បានអំពីការរៀបរាប់ទៅលើអត្តចរិតរបស់មេក្រុម <និង> មេកង នូវពាក្យពេចន៍ដែលបានយកមកប្រើប្រាស់។ គឺពាក្យដែលគេធ្លាប់បានប្រើប្រាស់ពាក់ព័ន្ធទៅនឹងកម្មាភិបាលថ្នាក់ក្រោម។ ដើម្បីបញ្ចប់ការជំទាស់តវ៉ារបស់ខ្ញុំគឺថាកម្មាភិបាលថ្នាក់លើ <ឬក៏ថ្នាក់កំពូលនៃបក្សកុម្មុយនីស្តកម្ពុជា> មិនចង់ឲ្យកម្មាភិបាលថ្នាក់ក្រោមមានឥរិយាបថបែបនោះនឹងនោះទេ។ <ហើយពួកគេពិតជាបានរៀបចំឲ្យកម្មាភិបាលថ្នាក់ក្រោម មិនត្រូវប្រព្រឹត្តឥរិយាបថរបៀបណាខ្លះ។ ហើយខ្ញុំចង់>កំណត់មើលថាតើ<អត្តចរិតទាំងអស់ហ្នឹងរបស់>កម្មាភិបាលថ្នាក់ក្រោម<ប្រព្រឹត្តចំពោះប្រជាជន ប្រហែលជាអាចរំឭកការចងចាំរបស់សាក្សីនេះ។ ដូច្នេះ>វាមានមូលហេតុផ្លូវច្បាប់ និងមូលហេតុពាក់ព័ន្ធទៅនឹងតថភាពពិត<នៃសំណួរនេះ>។

[១១:៣៤:០៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធានដែលផ្តល់វេទិកាឲ្យខ្ញុំជាថ្មី។ ខ្ញុំគ្រាន់តែធ្វើការកត់សម្គាល់ដ៏ខ្លីមួយដើម្បីឲ្យអង្គជំនុំជម្រះយល់និងពិចារណានៅពេលតុលាការធ្វើការសម្រេច។ ខ្ញុំយល់ថាពីតម្រូវការរបស់ភាគីទាំងអស់ដែលចង់ប្រើឯកសារដែលមិនត្រូវបានដាក់ចូលនៅក្នុងអ៊ីនធីហ្វេស<មុនហ្នឹងមួយថ្ងៃ>។ នេះមិនមែនជាបញ្ហាអ្វីទេចំពោះខ្ញុំ ព្រោះថាយើងមានលទ្ធភាពពិនិត្យមើលឯកសារនៅពេលសម្រាកអាហារថ្ងៃត្រង់នេះ ក៏ប៉ុន្តែសូមឲ្យអង្គជំនុំជម្រះច្បាស់ ថាបើសិនជាលើកលែងឲ្យមេធាវី កូប៉េ ឥឡូវនេះត្រូវតែក្រោយមកលើកលែងដល់ភាគីផ្សេងទៀតដែរ។ អ៊ីចឹងសូមឲ្យយើងច្បាស់ទាំងអស់គ្នា ថាយើងអាចមានលទ្ធភាពប្រើនៅពេលដែលយើងយល់ឃើញថាវាជាការចាំបាច់ គឺថាមានលទ្ធភាពប្រើឯកសារដែលមិនបានដាក់ចូលក្នុងអ៊ីនធីហ្វេសពេលមុនហ្នឹងមួយថ្ងៃ។ អ៊ីចឹង សូមឲ្យអង្គជំនុំជម្រះផ្តល់ មានភាពបត់បែនដូចគ្នា គឺថាសម្រាប់ភាគីផ្សេងទៀត បើសិនខកខានមិនបានដាក់ឯកសារចូលអ៊ីនធីហ្វេស។ នៅថ្ងៃមុនមានករណីចាំបាច់លើកលែងឲ្យដូចគ្នាលោកប្រធាន សុំយ៉ាងដូច្នេះ។

**ប្រធានអង្គជំនុំ៖**

បាទឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀលនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាក បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១១:៣៦ នាទី ដល់ម៉ោង១៣:៤៣ នាទី)*

[១៣:៤៣:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឆ្លើយបញ្ជាក់លើបញ្ហាឯកសារដែលមេធាវីការពារក្តី នួន ជា បានលើកឡើងស្នើសុំដាក់ពិភាក្សាដេញដោលតាំងសំណួរចុងក្រោយ តាំងសំណួរចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់ថានៅរសៀលនេះ ចៅក្រម ម៉ាទីន ខាវ៉ុបគីន លោកមានបញ្ហាសុខភាព ហើយលោកបានអវត្តមាននៅក្នុងកិច្ចដំណើរការសវនាការនៅរសៀលនេះ។

បាទសូម -- អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីធ្វើការបញ្ជាក់លើជំហររបស់ខ្លួននូវ ចំពោះឯកសារដែលបានដាក់កាលពីព្រឹកមិញដោយក្រុមមេធាវីការពារក្តីលោក នួន ជា។ ឯកសារចុងក្រោយ។

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។ យើងមិនជំទាស់ទៅនឹងការប្រើប្រាស់ជាក់លាក់នូវឯកសារនេះនៅក្នុងកាលៈទេសៈនេះទេ។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ថា ដោយសារតែឯកសារមានតែមួយទំព័រ ហើយមេធាវីការពារក្តីបានពន្យល់យ៉ាងច្បាស់អំពីចេតនារបស់គាត់ក្នុងការប្រើប្រាស់ឯកសារ ហើយយើងមានការឈប់សម្រាកពីរម៉ោងនៅពេលបាយថ្ងៃត្រង់ <ដើម្បីពិនិត្យឯកសារនេះឡើងវិញ។ បើសិនជាមានការលើកឡើងនូវចំណុចណាមួយខុសគ្នានោះ យើងនឹងជំទាស់។> បើសិនជាឯកសារវែង ហើយមេធាវី<>ការពារក្តី<មិនបានពន្យល់ប្រាប់>អំពីគោលបំណងរបស់ខ្លួនសម្រាប់ប្រើប្រាស់ឯកសារ ហើយ<បើសិនជា>យើងមានពេលវេលាតិច<តួច ដើម្បីពិនិត្យឯកសារហ្នឹងឡើងវិញ នោះ>យើងនឹងជំទាស់ហើយ។ ហើយហេតុផលដែលយើងនឹងជំទាស់នេះ គឺដោយសារថាមិនមានការជូនដំណឹងយើងឲ្យបានមុន គឺវាធ្វើឲ្យមានការប៉ះពាល់ដល់ការប្រើប្រាស់ឯកសារ។ <កាលណាឯកសារមិនត្រូវបានដាក់ឲ្យដឹង នៅខណៈពេលដែលយើង>មើលឯកសារនោះ<> មេធាវីការពារក្តី<ប្រហែល>បន្តសួរ<សំណួរទី២ និងទី៣> យើងក៏មិន<មានឱកាសដើម្បីពិនិត្យមើលថា តើវា>ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សីនេះដោយរបៀបណានោះទេ។ ដូច្នេះក្នុងន័យនេះ គឺថាយើងមិនទទួលយកនូវគំនិតដែលថាឯកសារនេះគឺភាគីទាំងអស់នៅក្នុងបន្ទប់សវនាការដឹង<ច្បាស់>ទាំងអស់នោះទេ។ នៅក្នុងសំណុំរឿងនេះដោយសារមានឯកសារច្រើន ដូច្នេះម្នាក់ៗមិនអាចចេះតែដឹងនូវ<ភាពខុសគ្នាទំព័រនីមួយៗ នៃឯកសារនីមួយ>នោះទេ ហើយ<នេះគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយ ដែលយើង>មានវិធានស្តីអំពីការជូនដំណឹងជាមុន<>។

[១៣:៤៦:៣០]

<ចំពោះឯកសារមួយនេះ គឺទស្សនាវដ្តីទង់បដិវត្ត គឺ>មានឯកសារជាច្រើននៅក្នុងសំណុំរឿង<ហើយឯកសារទាំងអស់នោះគឺមានច្រើនទំព័រ>។ ដូច្នេះយើងខ្ញុំយល់អំពីភាពបត់បែនដែលតម្រូវឲ្យមានការអនុវត្តកិច្ចដំណើរការនីតិវិធី ហើយយើងក៏យល់ឃើញថានៅក្នុងចំណុចខ្លះ គឺយើងក៏<ប្រហែលជា>សុំឲ្យអង្គជំនុំជម្រះមានភាពបត់បែនសម្រាប់យើងខ្ញុំផងដែរ។ តែទោះយ៉ាងណាក៏ដោយវិធាននៅតែជាវិធាន លើកលែង ករណីលើកលែងគឺជាករណីលើកលែង។ ដូច្នេះសម្រាប់ករណីពិសេសមួយនេះ លោកប្រធាន យើងខ្ញុំនឹងមិនជំទាស់ទេ <យើងខ្ញុំមិនចង់ឲ្យករណីនេះ វាទៅជាយល់ឃើញថាវាផ្ទុយនឹងវិធានជាមូលដ្ឋាន ដែលលោកប្រធានបានកំណត់ចំពោះការជូនដំណឹងឯកសារនោះ>។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមធ្វើការឆ្លើយតប។ វាជាចម្លើយមួយដែលគួរឱ្យចាប់អារម្មណ៍ណាស់ដោយសារថា វាដូចដែលសហព្រះរាជអាជ្ញាកាលពី<>សប្តាហ៍មុន គឺ<នៅពេលដែលគាត់បានសួរអ្នកជំនាញគឺ>បានប្រើប្រាស់ឯកសារដែលមិនបានដាក់អ៊ីនធីហ្វេសដែរ <ហើយយើងក៏មិនបានជំទាស់ដែរ>។ ដូច្នេះខ្ញុំគិតថា សំណួរនេះវា<>ពាក់ព័ន្ធទៅនឹងបញ្ហាទូលំទូលាយ ហើយគោលបំណងក្នុងការតាំងសំណួរ មិនមែនធ្វើឱ្យភាគីដទៃមានការភ្ញាក់ផ្អើល <ឬក៏ធ្វើឱ្យមានការភ្ញាក់ផ្អើលដល់អង្គជំនុំជម្រះ> នោះទេ។ ក៏ប៉ុន្តែពេលខ្លះ អារឿង<ហ្នឹងគឺលេចចេញឡើង>នៅក្នុងពេលតាំងសំណួរទៅកាន់សាក្សីដោយមិនបាន<>រៀបចំជាមុន។ ដូច្នេះយើងខ្ញុំយល់ឃើញថាយើងមិនគួរណាប្រកាន់យកនូវវិធានដែលមានលក្ខណៈ តឹងរ៉ឹងនោះទេ។ <ប៉ុន្តែបើយើងកំណត់ថា>ត្រូវតែការជូនដំណឹងទៅលើ អ៊ីនធីហ្វេស <ដោយមិនមានការបត់បែនក្នុងការដាក់ឯកសារនៅចំពោះមុខសាក្សី គឺថានៅក្នុងទ្រឹស្តី គឺភាគីទាំងអស់គួរតែត្រូវបានដឹង។ បន្ទាប់មក ខ្ញុំយល់ឃើញថា យើងកំពុងតែចូលដល់តំបន់មួយ ដែល>យើងមិនចង់ឱ្យមានបញ្ហាបែបហ្នឹងនេះនោះទេ<។ ដូច្នេះ ខ្ញុំយល់ឃើញថា>វិធានទូទៅគឺយើងត្រូវធ្វើការសម្រេចជាទូទៅ។ បើសិនណាឯកសារនេះភាគីទាំងអស់បានដឹង ហើយបានពិភាក្សាជាយូរលង់មកហើយនោះ <គឺនៅក្នុងសំណុំរឿង ០០២/០១> ភាគីមិនគួរមានការភ្ញាក់ផ្អើលនោះទេ។ <បើសិនជាឯកសារនេះមិនមាននៅក្នុងអ៊ីនធីហ្វេស ដើម្បីពិនិត្យមើលក៏ដោយ ប៉ុន្តែយើងក៏នៅតែអាចប្រើប្រាស់វាបានដែរ>។ អ៊ីចឹងនៅក្នុងពេលនេះប្រហែលជាការល្អ គឺយើងស្នើសុំឱ្យអង្គជំនុំជម្រះសម្រេចជារួមពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឯកសារក្នុងកាលៈទេសៈបែបនេះ។

[១៣:៤៩:២៧]

**លោក ត្រាវិស ហ្សារ៖**

ខ្ញុំសូមអធ្យាស្រ័យ ដែលក្រោកឡើងនិយាយម្តងទៀត។ លោក កូប៉េ បានរំឭកដល់ខ្ញុំនេះ។ តាមដែលខ្ញុំយល់ គោលបំណងរបស់គាត់ក្នុងការប្រើប្រាស់ឯកសារនេះ គឺដើម្បីធ្វើការជំទាស់តវ៉ាថាអត្តចរិតរបស់កម្មាភិបាលមូលដ្ឋានមិនស៊ីចង្វាក់គ្នាទៅនឹង<អ្វីដែលគាត់និយាយថាថ្នាក់កំពូលនោះ គឺ>ដែលបានកំណត់ក្នុងទស្សនាវដ្តីទង់បដិវត្ត នោះទេ<។ នៅក្នុងសំណើសុំរបស់យើង គឺវាមិនមែនជាបញ្ហាមួយដែលលើកឡើងនៅក្នុងអំឡុងពេលផ្តល់ភស្តុតាងរបស់សាក្សីរូបនេះទេ>។ ដូច្នេះយើងខ្ញុំយល់ថាជាការ<>ស្មានោះទេ មុននឹងការសួរទៅលើសាក្សីផ្ទាល់តែម្តង។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម៉េចទៅខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបានអានឯកសារឬនៅ? ហើយមានការផ្លាស់ប្ដូរនូវជំហរយ៉ាងម៉េចខ្លះលើបញ្ហានេះ ករណីជាក់លាក់ និងករណីទូទៅ ចំពោះបញ្ហានៃការដាក់ឯកសារអ៊ិនធីហ្វេសនេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ<នឹងប្រកាន់>គោលជំហរ <ដូចអ្វីដែលខ្ញុំបាននិយាយនៅ>មុនពេល<សម្រាក>បាយថ្ងៃត្រង់នេះ។ គឺដូចដែលលោក កូប៉េ បានលើកឡើងអ៊ីចឹង គឺថាវាជាការចាំបាច់<ត្រូវមានវិធានទូទៅមួយ ពាក់ព័ន្ធនឹងបញ្ហានេះ។> យើងត្រូវៗតែជូនដំណឹងដល់ភាគីមួយថ្ងៃមុន នូវឯកសារ ដែលយើងចង់ប្រើពេលសួរសំណួរ<ដេញដោល>។ អ៊ីចឹងវិធានហ្នឹងស្រួលទេ គឺថាជាការសួរតទល់<ចំពោះមុខ> មានចែងមកច្បាស់ហើយនៅក្នុងវិធានផ្ទៃក្នុងយើងនោះ។ អ៊ីចឹងភាគីមានកាតព្វកិច្ចជូនដំណឹងទៅភាគី ផ្សេងៗទៀតនូវឯកសារដែលខ្លួនចង់ប្រើក្នុងពេលខ្លួនសួរសំណួរទៅសាក្សី។ អ៊ីចឹង ខ្ញុំគិតថាវាពិបាកនឹងប្រឆាំងនឹង<គោលការណ៍ទូទៅ>នេះណាស់ <គឺថាគោលការណ៍នេះបានផ្ដល់មធ្យោបាយក្នុងការរៀបចំនូវការសួរដេញដោល។ ឥឡូវនេះ គ្រប់រឿងគឺត្រូវការបកប្រែ>។ អ៊ីចឹងបើសិនជាថា ឥឡូវនេះខ្ញុំអាចយល់ថាក្នុងលក្ខខណ្ឌមួយចំនួន ថាលើកលែងមួយចំនួនមានបញ្ហាកើតឡើង ហើយមានឯកសារដែលយើងមិនបានដាក់ចូលទៅក្នុងអ៊ិនធីហ្វេស គឺថាវាអាចកើតឡើងពីខាងសហព្រះរាជអាជ្ញា ពីខាងការពារក្ដី ឬពីខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី> គឺថា<ចំពោះ>លើកលែង<នេះ វាមិនមានបញ្ហាសម្រាប់ខ្ញុំនោះទេ។>។ ក៏ប៉ុន្តែ <វិធាន>ដែលខ្ញុំបានលើកឡើងមុននេះអម្បាញ់មិញ មុនពេលបាយថ្ងៃត្រង់ ខ្ញុំថា វិធានត្រូវតែគោរពទាំងអស់គ្នា ហើយ<យើងគួរតែត្រូវបានជូនដំណឹង>ផងដែរ <នៅពេលដែលមាន>ករណីលើកលែង <ចំពោះវិធាននេះ>។ អ៊ីចឹងគោលជំហររបស់ខ្ញុំនោះគឺថា សុំឱ្យរក្សាវិធានទាក់ទងនឹងការសួរតទល់<ចំពោះមុខ> ហើយនិងការប្រើប្រាស់អ៊ិនធីហ្វេស ដាក់ឯកសារមុនមួយថ្ងៃ<នៃសវនាការ។ ប៉ុន្តែករណីលើកឡើងមួយនៅក្នុងពេលធ្វើសវនាការនោះ យើង>មិនជំទាស់<ទៅនឹងការដាក់បង្ហាញអង្គហេតុនៃឯកសារទាំងអស់នោះដែរ បើសិនជាភាគីផ្សេងមានលទ្ធភាព>អានឯកសារ<ទាំងអស់នោះ> ហើយធ្វើយ៉ាងណាឱ្យយើងមានលទ្ធភាពសួរសំណួរទៅនឹងឯកសារ<ទាំងអស់នោះ>ផងដែរ។ <>នេះជាលក្ខខណ្ឌដែលត្រូវតែមាននៅក្នុងការសួរសំណួរដេញដោល<ចំពោះមុខ>។ អ៊ីចឹង<កាលណាបើមានឯកសារថ្មីបង្ហាញ នោះ>ភាគីទាំងអស់ <គួរតែមាន>សិទ្ធិសួរសំណួរថ្មីៗទាក់ទងទៅនឹង<ការប្រើ>ឯកសារ<ហ្នឹង>។ ហើយអ៊ីចឹងសូមឱ្យអង្គជំនុំជម្រះចេញជា<វិធាន

ទូទៅ>មួយមក ដើម្បីឱ្យភាគីទាំងអស់អាចដំណើរការសវនាការបានលោកប្រធាន។

[១៣:៥៣:២៣]

**ប្រធានអង្គជំនុំ៖**

ចុះឯកសារព្រឹកមិញនេះ? ឯកសារ E3/746 យ៉ាងម៉េចដែរ? បន្ទាប់ពីបានអាននូវឯកសារនេះ នៅពេលអាហារថ្ងៃត្រង់នេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

ខ្ញុំ<>ចង់ឱ្យអង្គជំនុំជម្រះចេញសេចក្ដីសម្រេច<ស្ដីអំពីវិធានទូទៅនេះ> មុននឹងពេលខ្ញុំផ្ដល់គំនិតទាក់ទងនឹងការប្រើឯកសារនេះ។ បើសិនជាអង្គជំនុំជម្រះអនុញ្ញាតឱ្យប្រើឯកសារនេះ ខ្ញុំមិនមាន<មានបញ្ហាអ្វីទេ ចំពោះការដាក់ឱ្យប្រើប្រាស់ឯកសារនេះ ដោយសហភាតារបស់យើង ក្នុងអំឡុងពេលសវនាការរសៀលនេះ>។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សូមបញ្ជាក់ឱ្យច្បាស់ថាគោលបំណងរបស់ខ្ញុំគឺមិនចាំបាច់ មិនមែនចាំបាច់សម្រាប់តែការដាក់ឯកសារ<ចំពោះសាក្សី>នោះទេ។ ការបារម្ភរបស់ខ្ញុំគឺការប្រើប្រាស់ពាក្យពេចន៍នៅក្នុងសហកាលនោះ <និងពាក្យពេចន៍របស់បដិវត្តន៍ គឺតាមអ្វីដែលខ្ញុំដឹងនោះ គឺគេលែងប្រើប្រាស់នៅក្នុងភាសាខ្មែរទៀតហើយ។ ដូច្នេះ វាមិនមែនថាគាត់ត្រូវតែស្គាល់ឯកសារនោះទេ ដោយសារតែគាត់មិនអាចធ្វើដូច្នេះឡើយ។ ដូច្នេះអ្វីដែលអ្នកបានឃើញហើយថា ពាក្យពេចន៍ទាំងអស់នោះ គឺលែងប្រើនៅក្នុងភាសាខ្មែរទៀតហើយ>។

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ដើម្បីបញ្ចៀសនូវការដេញដោលគ្នាតទៅមុខទៀត តើខ្ញុំយល់សំណើរបស់ភាគីត្រឹមត្រូវដែរឬទេ គឺថាពួកគេ>មិនជំទាស់ទៅនឹងការប្រើប្រាស់ឯកសារនេះ<នៅថ្ងៃនេះ>ទេ ដោយសារហេតុផលដូចដែលបានលើកឡើង ក៏ប៉ុន្តែភាគីមួយៗត្រូវចង់បាននូវការណែនាំមួយរបស់អង្គជំនុំជម្រះ ថាតើត្រូវប្រើប្រាស់យ៉ាងម៉េចតាមរយៈអ៊ីនធីហ្វេស<ក្នុងបរិបទទូទៅ។ តើខ្ញុំអ៊ីចឹងត្រឹមត្រូវដែរឬទេ?> ខ្ញុំមើលទៅគ្រប់ភាគីទាំងអស់បានងក់ក្បាល បើយ៉ាងដូច្នេះគឺថាយើងអាចបន្តសួរទៅបាន។

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ ជាមួយនឹងភាពខុសគ្នានេះ គឺថាយើងធ្លាប់មានការពិបាកក្នុងការតាំងសំណួរដេញដោល សំណួរកើតមានឡើងក្នុងអំឡុងពេលសាក្សីផ្តល់សក្ខីកម្ម ហើយយើងតែងតែទទួលបានប្រតិកម្មតប។ ហេតុដូច្នេះយើងខ្ញុំ គឺស្ថិតនៅក្នុងគោលជំហរខុសគ្នា។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<យើងនឹងពិចារណាអំពីបញ្ហានេះ> នៅពេលណាយើងធ្វើការដាក់ចេញនូវការសម្រេចជាទូទៅមួយ។ <ប៉ុន្តែយើងយល់ស្របជាមួយរឿងនេះដែរអត់? ថាយើងអាចបន្តទៅមុខទៀតបាន។> គឺយើងឃើញថា<ភាគីទាំងអស់>មានការយល់ស្របហើយ គឺថាឯកសារមួយនេះគឺថាមេធាវីការពារក្តីអាចប្រើប្រាស់បាន <នៅពេលនេះ ចំពោះបរិបទមួយនេះ> ដោយយោងទៅលើករណីលើកលែង។ <ចំពោះការយោគយល់នេះ គឺថានឹងមានចេញនូវវិធានការទូទៅមួយនាពេលខាងមុខ។ តើអ៊ីចឹងមែនទេ?>

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយលោកស្រីចៅក្រម។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ចាស គឺយល់ព្រមហើយ។>

**<លោកស្រី ម៉ារី ហ្គ្វីរ៉ូដ៍៖>**

<ចាស ជាការពិតហើយ។>

[១៣:៥៦:០៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី យើងបានពិភាក្សាគ្នាយូរអំពីបញ្ហាដែលវាមិនពាក់ព័ន្ធទៅនឹងលោកទេ។ នៅមុនពេលឈប់សម្រាកបាយថ្ងៃត្រង់ លោកនិយាយ<ខ្លីៗ>អំពីប្រធានកងនិងប្រធានក្រុមរបស់លោក។ ខ្ញុំចង់សួរ លោក ថាលោកអាចរៀបរាប់បើលោកចាំបានល្អ អំពីឥរិយាបថ អត្តចរិតក្នុងការអនុវត្តការងារ<ជា>មេក្រុម មេកងរបស់លោក។ តើគេមាន<ការប្រាស្រ័យទាក់ទង>យ៉ាងម៉េច<ជាមួយលោក និងជាមួយ>សមាជិក<ផ្សេងទៀតនៅក្នុងកងរបស់លោក>? តើមេកងរបស់លោកហ្នឹងមានអត្ត

ចរិតរបៀបម៉េច? មានអាកប្បកិរិយាបែបណា? ខ្ញុំចង់ឲ្យលោកផ្តល់ -- ខ្ញុំនឹងបង្ហាញពាក្យពីរបីពាក្យទៅលោក ចង់ដឹងថាតើពាក្យនេះវាអាចនឹងបកស្រាយ ឬថាកំណត់នូវអាកប្បកិរិយាមេកងរបស់លោកឬក៏យ៉ាងណា? ពាក្យទី១ តើពាក្យនេះវាអាចកំណត់អំពីអាកប្បកិរិយាមេកងរបស់លោកឬក៏អត់? គឺពាក្យថា "ផ្តាច់ការ"។

**លោក សៅ ប៉ាន៖**

**ឆ៖** ពាក្យថា "ផ្តាច់ការ" ខ្ញុំបានកំណត់ថាគឺប្រើពលកម្មផ្តាច់ការទៅលើកម្មករ កសិករជារៀងរាល់ថ្ងៃ។

**ស៖** តើសម្រាប់អាកប្បកិរិយារបស់គាត់ គឺៗជាអ្នកដែលបង្ហាញនូវជំហរបែបជានាហ្សីនិយម?

**ឆ៖** បាទ ជំហររបស់គណៈកម្មការកង ក្រុម គឺគេដាច់ខាតគឺគេតាំងចិត្តថាគេប្រើកម្មករ កសិករ ធ្វើម៉េចឲ្យបានគ្រប់ផែនការរបស់អង្គការគេ ប៉ុណ្ណឹង។

**ស៖** តើលោកអាចនឹងប្រើពាក្យថា"ឃោធានិយម"ដែរទេ បើកាលណានិយាយទៅដល់អាកប្បកិរិយានៃមេកង <ឬក៏ក្រុម>របស់លោក?

**ឆ៖** អាចនិយាយបានថា "ឃោធានិយម"។

[១៣:៥៩:២៦]

**ស៖** ខ្ញុំឮសួរបកប្រែទៅ ខ្ញុំប្រើពាក្យថា *"មីលីថារីស្ទីក"* គឺ "ឃោធានិយម"។ ខ្ញុំប្រើពាក្យថា "មីលីថារីស្ទីក" មិនមែន "*មេធើរៀលីស្ទីក*" ទេ – គឺ "ឃោធានិយម" មិនមែន "សម្ភារៈនិយម"ទេ។ ខ្ញុំក៏បានផ្តល់ឯកសារមួយទំព័រនេះទៅដល់អ្នកបកប្រែដែរ។ លោកសាក្សី លោកអាចរៀបរាប់ -- អាចៗនិយាយថាជាមេកង <ឬមេក្រុម>របស់លោកជា "មនុស្សឯកចិត្តនិយម" បានទេ?

**ឆ៖** មិនប៉ានទេ។

**ស៖** ខ្ញុំសល់ពាក្យពីរទៀត។ ចុះមួយទៀត តើលោកអាចនិយាយបានថាជាៗ "អ្នកការិយាល័យនិយម" បានទេ? "ការិយាល័យនិយម ឬក៏សេរីនិយម" អាចនិយាយអ៊ីចឹងបានទេ? "សេរីនិយម"?

**ឆ៖** អត់និយាយបានទេ។

**ស៖** បាទ ខ្ញុំឲ្យពាក្យពេជន៍ទាំងនេះដើម្បីចង់យល់ថាតើលោកអាចរៀបរាប់អាកប្បកិរិយារបស់មេក្រុម និងមេកងលោកដោយរបៀបណា? បើនិយាយជារួម តើលោកអាចប្រើពាក្យរបស់លោកដោយផ្ទាល់ដើម្បីរៀបរាប់អំពីអាកប្បកិរិយារបស់មេក្រុម ឬមេកងនេះបានទេ? លោកប្រើពាក្យរបស់លោក

ផ្ទាល់តែម្ដង។

**ធ៖** បាទ ខ្ញុំអត់ប៉ានប្រើទេ។

[១៤:០១:៥២]

**ស៖** ហេតុផលដែលខ្ញុំសួរបែបនេះ ដោយសារថាមុនពេលឈប់សម្រាកបាយថ្ងៃត្រង់ លោកបានឆ្លើយថាលោកខ្លាចមេកង នៅពេលណាប្រជាជននិយាយឬក៏ជំទាស់តវ៉ាអ្វីមួយគឺ -- ឬក៏អ្នកណាម្នាក់ធ្វើឲ្យបាក់ស្ពាបព្រាអ៊ីចឹង គឺ<គាត់បានបំភ័យប្រជាជនថានាំ>ខ្លួនចេញទៅបាត់។ ដូច្នេះខ្ញុំព្យាយាមស្វែងយល់ថា១តើនៅក្នុងអំឡុងពេលទាំងនោះ តើវាមានទំនាក់ទំនងគ្នាយ៉ាងម៉េចរវាងលោក សមាជិកនៅក្នុងក្រុមរបស់លោក កងរបស់លោកជាមួយមេកងហ្នឹង? ដូច្នេះសូមលោកមេត្តាជួយរៀបរាប់អំពីអាកប្បកិរិយារបស់បុគ្គលនេះឲ្យបានលម្អិតបន្តិច។

**ធ៖** ពេលណាមានបញ្ហាបាក់ស្ពាបព្រា បាក់អីខូចខាតអ៊ីចឹង គ្មានអ្នកណាមួយប៉ានទៅនិយាយទៅពិភាក្សាអីជាមួយមេកង មេក្រុមអីអត់ទាំងអស់។

**ស៖** បញ្ហាដែលខ្ញុំចង់ស្វែងយល់ឲ្យនោះ គឺថាតើហេតុអ្វីបានជាលោកផ្ទាល់នោះ ខ្លាចមេកង <?> ស្អីដែលធ្វើឲ្យ ដែលនាំឲ្យលោកខ្លាចមេកងហ្នឹង?

**ធ៖** នាំឲ្យខ្លាចមេកងឃើញពីមុនៗមកចេះតែបាត់មនុស្សពីក្រុមពីកងទៅចេះតែខ្លាច នឹកឃើញថាបាត់ទៅមិនដែលឃើញមកវិញ នឹកឃើញក្នុងចិត្តថាស្លាប់ហើយ អត់ប៉ាននិយាយអត់ប៉ានថាអីទេ។

[១៤:០៣:៤៦]

**ស៖** ប៉ុន្តែមុនពេលឈប់សម្រាកបាយថ្ងៃត្រង់ លោកក៏បានឆ្លើយអំពីការបាត់ខ្លួន គឺអ្នកដែលបាត់មុខ<ពីសហករណ៍ ឬ>កង ហើយអត់ឃើញត្រឡប់មកវិញ។ ខ្ញុំមិនចាំបាច់និយាយថាលុះណាតែមានអ្វីវាប៉ះពាល់ឬក៏ថាអ្វីដែលប៉ះពាល់ដល់រាងកាយ<>របស់អ្នកដែលបាត់ខ្លួននោះទេ។ លោកយល់បញ្ហានេះទេ?

**ធ៖** ខ្ញុំអត់យល់ទេ។

**ស៖** ខ្ញុំព្យាយាមសួរម្ដងទៀត។ ខ្ញុំយល់អំពីការភ័យខ្លាច<>ចំពោះអ្វីដែលអាចកើត <វាគឺជារឿងរបស់បុគ្គល ប៉ុន្តែខ្ញុំព្យាយាមដើម្បីស្វែងយល់ថា តើចំពោះរូប>លោកក្ដី ឬសមាជិកក្រុមរបស់លោកក្ដី ថាមានហេតុផលដែលនាំឲ្យខ្លាចមេក្រុម ឬមេកងដែរឬក៏យ៉ាងណា។ អ៊ីចឹងខ្ញុំព្យាយាម<រកឲ្យឃើញថា> តើគាត់បាននិយាយថាម៉េច? គាត់សម្ដែងនូវអត្តចរិតរបស់គាត់ ហ្នឹងយ៉ាងម៉េច<ចំពោះ

លោក>? ហើយថាតើមេកងមាន<ការប្រាស្រ័យទាក់ទងជាមួយលោករបៀបណា? អ្វីដែលនាំឲ្យលោកខ្លាចមេកង?

**ឆ៖** នាំឲ្យខ្ញុំខ្លាចមេកង ខ្ញុំមើលឃើញថា មនុស្សដែលរស់នៅជាមួយគ្នា ធ្វើការជាមួយគ្នាដែលបាត់ៗទៅៗ សង្ស័យថាមិនបានមកវិញ គឺខ្លាចរហូត។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំមានចំណុចមួយចុងក្រោយសម្រាប់ប្រធានបទនេះ គឺពាក់ព័ន្ធទៅនឹងស្ថានភាពចំណីអាហារ <និងការហូបរួម>។ ពីម្សិលមិញ យើងមានសាក្សីម្នាក់ផ្តល់សក្ខីកម្មដែលមកពីឃុំផ្សេងហើយគាត់បានជម្រាបជូនអង្គជំនុំជម្រះថា យោងទៅបញ្ជោជីវភាពពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនគាត់មានបាយហូប មានសម្ល មានត្រី ជួនកាលមានដល់សាច់គោ ហើយមានបន្លែ។ តើរបបបអាហារនៅក្នុងឃុំហ្នឹង វាដូចគ្នាទៅនឹងរបបអាហារនៅក្នុងសហករណ៍លោក <ឃុំលោក>ដែរទេ?

**ឆ៖** វាខុសគ្នាតិចតួចដែរនៅសហករណ៍ខ្ញុំ។ បន្លែមានពិត ប៉ុន្តែបន្លែហ្នឹងវា អើយើងធ្វើបានខ្លួនយើងក្នុងអង្គភាពដាំបន្លែហ្នឹង មានព្រលឹត មានត្រសក់ មានត្រឡាច មានល្ពៅ មានតែប៉ុណ្ណឹង។ សាច់គោ សាច់ជ្រូកអី វាមិនងាយដល់មានឲ្យបានជាញឹកញាប់អីទេ អត់ដែរសូវបានទេ កម្របានណាស់។

**ស៖** ចុះត្រីវិញ នៅក្នុងអង្គភាពនេសាទ កងនេសាទ គេមានចេញទៅស្ទូររកត្រី រកសាច់អីដែរទេនៅក្នុងសហករណ៍លោក?

**ឆ៖** នៅក្នុងសហករណ៍ខ្ញុំមានអ្នកនេសាទ ប៉ុន្តែតំបន់ខ្ញុំ មិនសូវមានបឹងបួធំដុំ បានតិចតួចដែរអត់មានបានទៅរកឯណាឆ្ងាយ។ ឃុំខ្ញុំនៅក្បែរភ្នំ វាគ្មានបឹងបួអីធំដុំអីទេ។ រក មានចាត់តាំងរក យកមកស្លមួយខ្ទះធំៗអីចឹងៗទៅ។ វាមួយចានសម្លហ្នឹងមានមួយដុំ ពីរដុំអីដែរ។ អាហ្នឹងខ្ញុំជម្រាបជូនតាមត្រង់។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែខ្ញុំសូមកែតម្រូវខ្លួនខ្ញុំផ្ទាល់។ ពីព្រឹកមិញខ្ញុំបាននិយាយអំពី<កំណាត់ត្រាចំនួនធ្វើស្រែហិកតាក្នុងមួយតោន។> ខ្ញុំប្រើពាក្យលេខ <> គឺ១៦ តែតាមពិត គឺ<១៤.៨>នោះទេ គឺកំណាត់ត្រានេះជាកំណាត់ត្រាបែបចិន គឺហៅ “ចាំង”។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ចំពោះក្រុមខៀវ សំផន មិនមានសំណួរសួរទៅសាក្សីរូបនេះទេ លោកប្រធាន។ សូមអរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:០៨:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១១:២៣]

**ប្រធានអង្គជំនុំ៖**

បាទ លោក សៅ ប៊ាន អង្គជំនុំជម្រះសូមអរគុណលោក ហើយដែលបានអញ្ជើញមកផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ ហើយរួមទាំងម្សិលមិញមួយរសៀលដែរ។ ហើយដំណើរការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ វត្តមានរបស់លោកនៅអ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅៗកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកចង់ទៅបានហើយ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់ចង់ទៅបានហើយ។

ហើយឥឡូវនេះ ដោយសារមានបញ្ហាពាក់ព័ន្ធជាមួយនឹងឯកសារនេះសំណើសុំវិធានការការពាររបស់សាក្សីបន្ទាប់ទៅនេះ ហើយដើម្បីឲ្យបានប្រាកដនោះ គឺអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ -- ម៉ោងពីរកន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការ។ អង្គជំនុំជម្រះយកពេលវេលានេះ ដើម្បីពិភាក្សាសម្រេចលើៗបញ្ហានៃសំណើសុំវិធានការការពាររបស់សាក្សីដែលនឹងផ្តល់សក្ខីកម្មបន្តបន្ទាប់ទៀតនេះ។

បាទសម្រាកសិនចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:១២ នាទី ដល់ម៉ោង១៤:៣៩ នាទី)*

[១៤:៣៩:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសូមជម្រាបដល់ភាគីនិងសាធារណជនថា អង្គជំនុំជម្រះទើបតែទទួលបាននូវសំណើសុំវិធានការការពាររបស់សាក្សីមួយចំនួន។ ហើយលើសំណើសុំការការពារនេះ អង្គភាពគាំពារ

សាក្សីនិងអ្នកជំនាញ បាននិងកំពុងតែដំណើរការវាយតម្លៃ និងធ្វើរបាយការណ៍។ ហើយតាមកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ តម្រូវឱ្យមានបីភាសាប្រើការនៅ អ.វ.ត.ក។ ហើយដោយលទ្ធភាពនេះ មិនទំនងជាមិនអាចធ្វើបានទាន់ទេ ហើយអង្គជំនុំជម្រះនឹងបញ្ជូនទៅភាគីនានានៅថ្ងៃស្អែក។

សវនាការស្តាប់សក្ខីកម្មសាក្សី TCW-944 នឹងលើកទៅធ្វើនៅថ្ងៃស្អែក ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០១៥។ ហើយនៅថ្ងៃ សវនាការនៅថ្ងៃស្អែកនេះ នៅដើមដំបូងនៃដំណើរការសវនាការនាពេលព្រឹក អង្គជំនុំជម្រះទំនងជានឹងធ្វើសវនាការជាអសាធារណៈ ដើម្បីពិភាក្សាលើសំណើសុំឱ្យមានវិធានការការពារ។ នេះសូមភាគីជ្រាប។

ដូច្នេះសវនាការនៅថ្ងៃនេះ គឺអង្គជំនុំជម្រះផ្អាកត្រឹមនេះ។ ហើយបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការសហការជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនសាក្សីបម្រុង 2-TCW-944 ទៅទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ។ ហើយនិងបង្គាប់ឱ្យអញ្ជើញគាត់វិលត្រលប់មកចូលរួមផ្តល់សក្ខីកម្មចំពោះ អ.វ.ត.ក នៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រលប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រលប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឱ្យបានមុនៗម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៤:៤២ នាទី)*